

# ឯកសារគោលនៃចំណេះចំណានខាងគោលលទ្ធិ

ខែ មីនា ឆ្នាំ ២០១៨

# ឯកសារគោលនៃចំណោះចំណានខាងគោលលទ្ធិ

បានបោះពុម្ពដោយ
សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ
ទីក្រុង សលត៍ លេក រដ្ឋ យូថាហ៍

សូមថ្លែងអំណរគុណចំពោះយោបល់ និង ការកែលម្អ ។ សូមផ្ញើយោបល់ និង ការកែលម្អទាំងនោះ រួមទាំងកំហុសឆ្គងទាំងឡាយមកកាន់ ៖

Seminaries and Institutes of Religion Curriculum Services
50 East North Temple Street
Salt Lake City, Utah 84150-0008
USA

អ៊ីម៉ែល ៖ cesmanuals@ldschurch.org

សូមសរសេរ ឈ្មោះពេញ អាសយដ្ឋានវួដ ឬសាខា និងស្តេក ឬមណ្ឌលរបស់អ្នក ។
សូមកុំភ្លេចសរសេរចំណងជើងសៀវភៅសិក្សានៅពេលអ្នកផ្តល់មតិយោបល់របស់អ្នក ។

© ២០១៨ by Intellectual Reserve, Inc.
All rights reserved
បានបោះពុម្ពនៅសហរដ្ឋអាមេរិក
កំណែ ២, ៣/១៨

អនុមតិជាភាសាអង់គ្លេស ៖ ៦/១៧
អនុមតិការបកប្រែ ៖ ៦/១៧
ការបកប្រែនៃ *Doctrinal Mastery Core Document*
English
PD60004399 258

# មាតិកា


សេចក្តីណែនាំស្តីពីចំណេះចំណានខាងគោលលទ្ធិ . . . ១
ការទទួលបានចំណេះដឹងខាងវិញ្ញាណ . . . ៣
ប្រធានបទខាងគោលលទ្ធិ . . . ៦
១. ក្រុមព្រះ . . . ៧
២. ផែនការនៃសេចក្តីសង្គ្រោះ . . . ៩
៣. ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ . . . ១២
៤. ការស្តារឡើងវិញ . . . ១៤
៥. ព្យាការី និង វិវរណៈ . . . ១៦
៦. បព្វជិតភាព និង កូនសោទាំងឡាយនៃបព្វជិតភាព . . . ១៧
៧. ពិធីបរិសុទ្ធ និងសេចក្តីសញ្ញាទាំងឡាយ . . . ១៩
៨. អាពាហ៍ពិពាហ៍ និង គ្រួសារ . . . ២១
៩. បទបញ្ញត្តិទាំងឡាយ . . . ២២
វគ្គចំណេះចំណានខាងគោលលទ្ធិ . . . ២៣
វគ្គចំណេះចំណានខាងគោលលទ្ធិតាមប្រធានបទ និង វគ្គសិក្សា . . . ២៤
វគ្គចំណេះចំណាន ខាងគោលលទ្ធិ និងឃ្លាសំខាន់ៗ . . . ២៥

# សេចក្ដីណែនាំស្ដីពីចំណេះចំណានខាងគោលលទ្ធិ



នៅក្នុងព្រះគម្ពីរមរមន ព្យាការីហេលេមិនបានបង្រៀនកូនប្រុសរបស់លោកថា « គឺនៅលើសិលានៃព្រះដ៏ប្រោសលោះនៃយើងគឺព្រះគ្រីស្ទជាព្រះរាជបុត្រានៃព្រះ ដែលកូនត្រូវសង់គ្រឹះរបស់កូន » ( ហេលេមិន ៥:១២ ) ។ ការសង់គ្រឹះមួយនៅលើព្រះយេស៊ូវគ្រីស្ទ—ដែលរួម មានទាំងការយល់ ការជឿ និងការរស់នៅស្របតាមគោលលទ្ធិរបស់ទ្រង់—នឹងធ្វើឲ្យការផ្លាស់ប្រែចិត្ត ជឿ និង ការតាំងចិត្តរបស់យើងក្នុងនាមជាពួក សិស្សរបស់ទ្រង់កាន់តែស៊ីជម្រៅរឹងមាំ ដើម្បីការពារយើងពីឥទ្ធិពលរបស់មារសត្រូវ ហើយជួយយើងឲ្យប្រទានពរដល់ជីវិតអ្នកដទៃទៀត ។

វិធីមួយដែលយើងសម្រេចកិច្ចការនេះ គឺតាមរយៈការសិក្សាបទគម្ពីរតាមលំដាប់លំដោយជាមួយគ្នានៅក្នុងថ្នាក់ ។ របៀបមួយទៀតដែលយើងសង់គ្រឹះរបស់យើងលើព្រះយេស៊ូវគ្រីស្ទ និងគោលលទ្ធិរបស់ទ្រង់ គឺតាមរយៈកិច្ចខិតខំមួយ ដែលហៅថាចំណេះចំណានខាងគោលលទ្ធិ ។

ចំណេះចំណានខាងគោលលទ្ធិផ្ដោតទៅលើលទ្ធផលចំនួនពីរ ៖

១. ការរៀនសូត្រ និងការអនុវត្តគោលលទ្ធិដ៏ទេវភាពដើម្បីទទួលបានចំណេះដឹងខាងវិញ្ញាណ

   ព្រះវរបិតាសួគ៌បានបើកសម្ដែងគោលការណ៍ទាំងឡាយដើម្បីទទួលបានចំណេះដឹងខាងវិញ្ញាណ ។ គោលការណ៍ទាំងនេះរួមមានទាំងការធ្វើសកម្មភាពដោយសេចក្ដីជំនឿ ការពិនិត្យមើលគោលគំនិត និងសំណួរទាំងឡាយជាមួយនឹងទស្សនវិស័យដ៏អស់កល្បមួយ ហើយនឹងការស្វែងរកការយល់ដឹងបន្ថែមតាមរយៈប្រភពដែលបានតែងតាំងដ៏ទេវភាព ។ យើងចេះចំណេះចំណានខាងគោលលទ្ធិកាន់តែខ្លាំង នៅពេលយើងអនុវត្តគោលការណ៍ទាំងនេះទាំងនៅ ក្នុងថ្នាក់រៀន និងក្រៅថ្នាក់រៀន ហើយស្វែងរកចម្លើយចំពោះសំណួរខាងគោលលទ្ធិ និងសំណួរខាងប្រវត្តិសាស្ត្រនានាតាមរបៀបមួយដែលយាងអញ្ជើញព្រះវិញ្ញាណបរិសុទ្ធឲ្យជួយពង្រឹងសេចក្ដីជំនឿរបស់យើងទៅលើព្រះយេស៊ូវគ្រីស្ទ និងគោលលទ្ធិរបស់ទ្រង់ ។

២. ការចេះស្ទាត់នូវគោលលទ្ធិនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ និងវគ្គបទគម្ពីរទាំងឡាយដែលបង្រៀនអំពីគោលលទ្ធិ

   លទ្ធផលនៃចំណេះចំណានខាងគោលលទ្ធិនេះ នឹងត្រូវបានសម្រេចតាមរយៈ ៖

   a. ការអភិវឌ្ឍការយល់ដឹងកាន់តែស៊ីជម្រៅមួយអំពីប្រធានបទនីមួយៗក្នុងចំណោមប្រធានបទ នៃ គោលលទ្ធិទាំងប្រាំបួន ដូចខាងក្រោមនេះ ៖

      - ក្រុមព្រះ
      - ផែនការនៃសេចក្ដីសង្គ្រោះ
      - ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ
      - ការស្ដារឡើងវិញ
      - ព្យាការី និង វិវរណៈ
      - បព្វជិតភាព និង កូនសោនៃបព្វជិតភាព

- ពិធីបរិសុទ្ធ និង សេចក្តីសញ្ញា
- អាពាហ៍ពិពាហ៍ និង គ្រួសារ
- ព្រះបញ្ញត្តិ

b. ការយល់ដឹងសេចក្តីថ្លែងសំខាន់ៗស្តីពីគោលលទ្ធិដែលបានស្គាល់នៅក្នុងវគ្គ« ការទទួលបានចំណេះដឹងខាងវិញ្ញាណ »នៃឯកសារនេះ និងនៅក្នុងប្រធានបទនីមួយៗក្នុងចំណោមប្រធានបទនៃគោលលទ្ធិទាំងប្រាំបួន ។

c. ដឹងពីរបៀបដែលសេចក្តីថ្លែងការណ៍សំខាន់ៗអំពីគោលលទ្ធិត្រូវបានបង្រៀន នៅក្នុងវគ្គបទគម្ពីរចំណេះចំណានខាងគោលលទ្ធិ ហើយអាចចងចាំ និងរកវគ្គគម្ពីរទាំងនោះឃើញ ។

d. ពន្យល់សេចក្តីថ្លែងការណ៍សំខាន់ៗអំពីគោលលទ្ធិនីមួយៗច្បាស់លាស់ដោយប្រើវគ្គបទគម្ពីរចំណេះចំណានខាងគោលលទ្ធិដែលជាប់ទាក់ទង ។

e. ការអនុវត្តគោលលទ្ធិនៃ ដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងការជ្រើសរើសប្រចាំថ្ងៃរបស់យើង និងនៅក្នុងការឆ្លើយតបចំពោះសំណួរ និងបញ្ហាខាងគោលលទ្ធិ ខាងសង្គម និងខាងប្រវត្តិសាស្ត្រនានា ។

# ការទទួលបានចំណេះដឹងខាងវិញ្ញាណ



## ព្រះគឺជាប្រភពនៃរាល់សេចក្តីពិត

ព្រះជ្រាបដឹងនូវអ្វីៗគ្រប់យ៉ាង ហើយទ្រង់គឺជាប្រភពនៃសេចក្តីពិតទាំងអស់ ( សូមមើល ម៉ូសាយ ៤:៩ ) ។ ដោយសារព្រះវរបិតាសួគ៌របស់យើងស្រឡាញ់យើង ហើយចង់ឲ្យយើងរីកចម្រើនឆ្ពោះទៅរកការប្រែក្លាយដូចជាទ្រង់ នោះទ្រង់បានលើកទឹកចិត្តយើងឲ្យ « ស្វែងរកការរៀនសូត្រ គឺដោយសារការសិក្សា និងដោយសារសេចក្តីជំនឿផង » ( គ. និង ស. ៨៨:១១៨ ) ។ នៅក្នុងការស្វែងរកសេចក្តីពិតរបស់យើង យើងអាចទុកចិត្តលើទ្រង់ទាំងស្រុង ដោយពឹងផ្អែកទៅលើប្រាជ្ញារបស់ទ្រង់ សេចក្តីស្រឡាញ់របស់ទ្រង់ និងព្រះចេស្តារបស់ទ្រង់ដើម្បីបង្រៀន និងប្រទានពរដល់យើង ។ ព្រះបានសន្យាថានឹងបើកសម្តែងសេចក្តីពិតដល់គំនិត និងដួងចិត្តរបស់យើងតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ប្រសិនបើយើងនឹងស្វែងរកទ្រង់ដោយឧស្សាហ៍ព្យាយាម ( សូមមើល គ. និង ស. ៨:២-៣ ) ។

២. ដើម្បីជួយយើង ព្រះវរបិតាសួគ៌បានបង្រៀនយើងអំពីរបៀបដើម្បីទទួលបានចំណេះដឹងខាងវិញ្ញាណ ។ ទ្រង់បានបង្កើតលក្ខខណ្ឌនានា ដែលយើងត្រូវធ្វើតាមដើម្បីទទួលបានចំណេះដឹងដូច្នោះ ។ លំនាំដែលបានតែងតាំងដ៏ទេវភាពរបស់ព្រះតម្រូវឲ្យយើងមានបំណងប្រាថ្នាដ៏ស្មោះត្រង់ដើម្បីដឹងពីសេចក្តីពិត ( សូមមើលម៉ូរ៉ូណៃ ១០:៤-៥ )ហើយមានឆន្ទៈរស់នៅស្របតាមអ្វីដែលទ្រង់បានបើកសម្តែង ( សូមមើលយ៉ូហាន ៧:១៧ ) ។ បំណងប្រាថ្នាដ៏ស្មោះត្រង់របស់យើង នឹងដឹកនាំយើងឲ្យស្វែងរកសេចក្តីពិតតាមរយៈការអធិស្ឋាន ( សូមមើល យ៉ាកុប ១:៥-៦,នីហ្វៃទី ២ ៣២:៨-៩ ) និងការសិក្សាបន្ទូលរបស់ព្រះដោយឧស្សាហ៍ព្យាយាម ( សូមមើលធីម៉ូថេទី ២ ៣:១៥-១៧,នីហ្វៃទី ២ ៣២:៣ ) ។

## ការសួរសំណួរ និងការស្វែងរកចម្លើយ

៣. ពេលខ្លះយើងអាចនឹងរកឃើញព័ត៌មានថ្មី ឬមានសំណួរទាក់ទងនឹងគោលលទ្ធិ ការអនុវត្ត ឬប្រវត្តិសាសនាចក្រ ដែលហាក់ដូចជាពិបាកយល់ ។ ការសួរសំណួរ និងការស្វែងរកចម្លើយ គឺជាផ្នែកដ៏សំខាន់មួយនៃការខិតខំរបស់យើងដើម្បីរៀនអំពីសេចក្តីពិត ។ សំណួរខ្លះដែលកើតមានក្នុងគំនិតរបស់យើង អាចនឹងត្រូវបានបំផុសគំនិតដោយព្រះវិញ្ញាណបរិសុទ្ធ ។ សំណួរបំផុសគំនិតនានា គួរតែត្រូវបានចាត់ទុកថាជាអំណោយទានមកពីព្រះ ដែលបានប្រទានឱកាសដល់យើងឲ្យបង្កើនការយល់ដឹងរបស់យើង ហើយពង្រឹងដល់ការអះអាងរបស់យើងថាព្រះអម្ចាស់មានព្រះទ័យបង្រៀនដល់យើង ។ មិនថាសំណួររបស់យើងចេញមកពីប្រភពណាទេ យើងត្រូវបានប្រទានពរឲ្យមានលទ្ធភាពដើម្បីគិត និងរកហេតុផលហើយមានឥទ្ធិពលរបស់ព្រះអម្ចាស់ដើម្បីពង្រីកគំនិតរបស់យើង ហើយពង្រីកដល់ការយល់ដឹងក្នុងគំនិតរបស់យើងកាន់តែខ្លាំង ។ ឥរិយាបទ និងបំណងប្រាថ្នាដែលយើងសួរសំណួរ និងស្វែងរកចម្លើយនឹងមានឥទ្ធិពលយ៉ាងខ្លាំងទៅលើសមត្ថភាពរបស់យើងដើម្បីរៀនសូត្រតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។

៤. គោលលទ្ធិទាំងបីដូចទៅនេះអាចដឹកនាំយើងនៅពេលយើងព្យាយាមរៀនសូត្រ និងយល់ដឹងអំពីសេចក្ដីពិតដ៏អស់កល្បជានិច្ច ហើយដោះស្រាយសំណួរ ឬបញ្ហានានា ។

- ធ្វើសកម្មភាពដោយសេចក្ដីជំនឿ ។
- ពិនិត្យមើលគោលគំនិត និងសំណួរទាំងឡាយដោយទស្សនវិស័យដ៏អស់កល្បមួយ ។
- ព្យាយាមយល់ដឹងបន្ថែម តាមរយៈធនធានដែលបានប្រទានមកពីព្រះ ។

## គោលការណ៍ទី ១ ៖ ធ្វើសកម្មភាពដោយសេចក្ដីជំនឿ

៥. យើងធ្វើសកម្មភាពដោយសេចក្ដីជំនឿនៅពេលយើងជ្រើសរើសទុកចិត្តលើព្រះ ហើយបែរទៅរកទ្រង់ជាដំបូងបំផុត តាមរយៈការអធិស្ឋានដោយស្មោះត្រង់ សិក្សាការបង្រៀនរបស់ទ្រង់ ហើយគោរពប្រតិបត្តិតាមបទបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។

៦.នៅពេលយើងព្យាយាមអភិវឌ្ឍការយល់ដឹងរបស់យើង ហើយដោះស្រាយកង្វល់នានា នោះវាសំខាន់ណាស់ដែលយើងត្រូវពឹងផ្អែកទៅលើទីបន្ទាល់ដែលយើងមានរួចទៅហើយអំពីព្រះយេស៊ូវគ្រីស្ទ ការស្ដារឡើងវិញនៃដំណឹងល្អរបស់ទ្រង់ និងការបង្រៀនរបស់ពួកព្យាការីដែលបានតែងតាំងដោយទ្រង់ ។ អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនថា « ពេលគ្រាទាំងនោះមកដល់ ហើយបញ្ហានានាបង្ហាញជារូបរាងឡើង នោះដំណោះស្រាយមិនបានកើតឡើងភ្លាមៗទេ សូមកាន់ខ្ជាប់ទៅនឹងអ្វីដែលអ្នកបានដឹងរួចហើយ ហើយឈរយ៉ាងរឹងមាំរហូតដល់ចំណេះដឹងបន្ថែមទៀតមកដល់« ខ្ញុំជឿហើយ លោកម្ចាស់អើយ »*Ensign*ឬ *Liahona*ខែ ឧសភា ឆ្នាំ ២០១៣ ទំព័រ ៩៤ ) ។ ព្រះអម្ចាស់ផ្ទាល់បានអញ្ជើញយើងឲ្យ « មើលទៅ [ ទ្រង់ ] ដោយនូវគ្រប់ទាំងគំនិត ចូរកុំសង្ស័យ កុំខ្លាចឡើយ » ( គ. និង ស. ៦:៣៦ ) ។

៧. អំឡុងពេលដែលយើងរកមិនឃើញចម្លើយភ្លាមៗចំពោះសំណួររបស់យើង វាជាជំនួយដើម្បីចងចាំថា ទោះបីជាព្រះវរបិតាសួគ៌បានបើកសម្ដែងអ្វីៗទាំងអស់ដែលចាំបាច់សម្រាប់សេចក្ដីសង្គ្រោះរបស់យើងក្តី ក៏ទ្រង់ពុំទាន់បានបើកសម្ដែងសេចក្ដីពិតទាំងអស់ដែរ ។ នៅពេលយើងបន្តស្វែងរកចម្លើយ នោះយើងត្រូវតែរស់នៅដោយសេចក្ដីជំនឿ—ទុកចិត្តថាយើងនឹងទទួលបានចម្លើយដែលយើងស្វែងរកនៅទីបំផុត ( សូមមើលសុភាសិត ៣:៥-៦,អេធើរ ១២:៦ ) ។ នៅពេលយើងស្មោះត្រង់ចំពោះសេចក្ដីពិត និងពន្លឺ ដែលយើងបានទទួលរួចហើយនោះ នោះយើងនឹងទទួលបានវាបន្ថែមទៀត ។ ចម្លើយចំពោះសំណួរ និងការអធិស្ឋានរបស់យើង ជាញឹកញាប់កើតមាន « មួយបន្ទាត់ម្ដងៗ មួយសិក្ខាបទម្ដងៗ » ( នីហ្វៃទី ២ ២៨:៣០ ) ។

## គោលការណ៍ទី២ ៖ ពិនិត្យមើលគោលគំនិត និងសំណួរទាំងឡាយដោយទស្សនវិស័យដ៏អស់កល្បមួយ

៨. ដើម្បីពិនិត្យមើលគោលគំនិតខាងគោលលទ្ធិ សំណួរខាងគោលលទ្ធិ និងបញ្ហាសង្គមដោយទស្សនវិស័យដ៏អស់កល្បជានិច្ចមួយ នោះយើងគួរពិចារណាវាក្នុងបរិបទនៃផែនការនៃសេចក្ដីសង្គ្រោះ និងការបង្រៀនទាំងឡាយរបស់ព្រះអង្គសង្គ្រោះ ។ យើងស្វែងរកជំនួយមកពីព្រះវិញ្ញាណបរិសុទ្ធ ដើម្បីមើលឃើញនូវរឿងទាំងឡាយដូចជាព្រះអម្ចាស់ទតឃើញ( សូមមើល កូរិនថូសទី ១ ២:៥, ៩–១១ ) ។ ការធ្វើដូចនេះ អនុញ្ញាតឲ្យយើងព្រាងសំណួរជាថ្មី ( ដើម្បីមើលទៅសំណួរតាមរបៀបផ្សេង ) ហើយមើលទៅគំនិតនានាដោយផ្អែកទៅលើបទដ្ឋាននៃសេចក្ដីពិតរបស់ព្រះអម្ចាស់ ជាជាងដោយការទទួលយកការសន្មត ឬការប៉ាន់ស្មានរបស់លោកិយ ។ យើងធ្វើដូចនេះដោយការសួរសំណួរដូចជា « តើខ្ញុំបានដឹងអ្វីខ្លះអំពីព្រះវរបិតាសួគ៌ និងផែនការរបស់ទ្រង់រួចហើយនោះ ហើយតើទ្រង់បានទាក់ទងនឹងកូនចៅរបស់ទ្រង់ដោយរបៀបណា ? » និងសំណួរ « តើការបង្រៀនដំណឹងល្អអ្វីខ្លះដែលទាក់ទង ឬបញ្ជាក់អំពីគោលគំនិត ឬបញ្ហានេះ ? »

៩. ទោះជាសំណួរទាក់ទងនឹងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រក្តី ក៏វាអាចនឹងចាំបាច់ត្រូវពិនិត្យមើលដោយទស្សនវិស័យដ៏អស់កល្បជានិច្ចមួយដែរ ។ នៅពេលយើងបោះយុថ្កានៃទំនុកចិត្តរបស់យើងទៅលើព្រះវរបិតាសួគ៌ និងផែនការនៃសេចក្ដីសង្គ្រោះរបស់ទ្រង់ នោះយើងអាចមើលឃើញបញ្ហានានាកាន់តែច្បាស់ ។ វាអាចនឹងជួយយើងឲ្យពិនិត្យមើលសំណួរខាងប្រវត្តិសាស្ត្រតាមបរិបទប្រវត្តិសាស្ត្រត្រឹមត្រូវផងដែរ ដោយពិចារណាអំពីវប្បធម៌ និងបទដ្ឋាននៃវេលាកាលនោះ ជាជាងការដាក់បង្ខំឲ្យទទួលយកទស្សនវិស័យ និងឥរិយាបថនាពេលបច្ចុប្បន្ននេះ ។

១០. វាសំខាន់ដើម្បីចងចាំថា រឿងលម្អិតខាងប្រវត្តិសាស្ត្រពុំមាននូវអំណាចសង្គ្រោះនៃពិធីបរិសុទ្ធ សេចក្ដីសញ្ញា និងគោលលទ្ធិនោះទេ ។ ការត្រូវរំខានដោយរឿងលម្អិតដែលមិនសូវសំខាន់ ធ្វើឲ្យយើងភ្លេចអព្ភូតហេតុដែលបានបើកសម្ដែងអំពីការស្ដារឡើងវិញ គឺដូចជាការចំណាយពេលវិភាគទៅលើប្រអប់កាដូ ហើយមិនខ្វល់អំពីអំណោយដ៏អស្ចារ្យនៅក្នុងប្រអប់កាដូដូច្នោះដែរ ។

## គោលការណ៍ទី ៣ ៖ ការស្វែងរកការយល់ដឹងបន្ថែមតាមរយៈប្រភពដែលបានតែងតាំងដ៏ទេវភាព

១១. ជាចំណែកនៃដំណើរការដែលបានតែងតាំងរបស់ព្រះអម្ចាស់ដើម្បីទទួលបានចំណេះដឹងខាងវិញ្ញាណ នោះទ្រង់បានបង្កើតប្រភពជាច្រើនតាមរយៈអ្វីដែលទ្រង់បើកសម្ដែងសេចក្ដីពិត និងការណែនាំដល់កូនចៅរបស់ទ្រង់ ។ ប្រភពទាំងនេះ រួមមាន ពន្លឺនៃព្រះគ្រីស្ទ ព្រះវិញ្ញាណបរិសុទ្ធ បទគម្ពីរ ឪពុកម្ដាយ និងអ្នកដឹកនាំសាសនាចក្រ ។ គណៈប្រធានទីមួយ និងកូរ៉ុមនៃពួកសាវកដប់ពីរនាក់—ពួកព្យាការីរបស់ព្រះអម្ចាស់នៅលើផែនដីសព្វថ្ងៃនេះ—គឺជាប្រភពដ៏សំខាន់នៃសេចក្ដីពិត ។ ព្រះអម្ចាស់បានជ្រើសរើស ហើយបានតែងតាំងបុគ្គលម្នាក់ៗទាំងនេះដើម្បីនិយាយជំនួសទ្រង់ ។

១២. យើងអាចរៀនសេចក្ដីពិតតាមរយៈប្រភពដែលគួរឲ្យទុកចិត្តផ្សេងៗទៀតផងដែរ ។ ទោះជាយ៉ាងណាក៏ដោយ អ្នកស្វែងរកសេចក្ដីពិតដ៏ស្មោះត្រង់ គួរតែប្រុងប្រយ័ត្នចំពោះប្រភពព័ត៌មានដែលមិនគួរទុកចិត្តផងដែរ ។ យើងរស់នៅក្នុងគ្រាមួយ ដែលមានមនុស្សជាច្រើន « រាប់សេចក្ដីអាក្រក់ថាជាល្អ ហើយសេចក្ដីល្អថាជាអាក្រក់វិញ » ( អេសាយ ៥:២០ ) ។ សាតាំងគឺជាបិតានៃសេចក្ដីកុហក ហើយព្យាយាមបង្ខូចសេចក្ដីពិត រួចអូសទាញយើងឲ្យងាកចេញពីព្រះអម្ចាស់ និងពួកអ្នកបម្រើដែលបានតែងតាំងរបស់ទ្រង់ ។ នៅពេលយើងងាកទៅរកចម្លើយ និងការដឹកនាំមកពីប្រភពដែលបានតែងតាំងដ៏ទេវភាពរបស់ព្រះអម្ចាស់ នោះយើងអាចត្រូវបានប្រទានពរឲ្យចេះបែងចែករវាងសេចក្ដីពិត និងកំហុសឆ្គង ។ ការរៀនស្គាល់ និងចៀសចេញពីប្រភពមិនគួរឲ្យជឿ អាចការពារយើងកុំឲ្យភាន់ច្រឡំ និងការពារយើងពីអ្នកទាំងឡាយដែលព្យាយាមបំផ្លាញសេចក្ដីជំនឿយើង ។

## ការជួយដល់អ្នកដទៃឲ្យទទួលបានចំណេះដឹងខាងវិញ្ញាណ

១៣. នៅពេលអ្នកដទៃមកកាន់យើងដោយមានសំណួរ ឬចង់រៀនអំពីគោលលទ្ធិ ការអនុវត្ត ឬប្រវត្តិរបស់សាសនាចក្រ តើយើងអាចជួយពួកគេនៅក្នុងការស្វែងរកសេចក្តីពិតរបស់ពួកគេយ៉ាងដូចម្តេច ? ខាងក្រោមនេះ គឺជារបៀបមួយចំនួនដែលយើងអាចជួយពួកគេ ៖

១៤. ស្តាប់ដោយយកចិត្តទុកដាក់ និងដោយការអធិស្ឋាន ៖ស្តាប់ដោយយកចិត្តទុកដាក់ពីមុនអ្នកឆ្លើយ ព្យាយាមបញ្ជាក់ និងយល់ពីសំណួរដែលពួកគេមានជាក់ស្តែង ។ ព្យាយាមយល់ពីបំណងពិតនៃសំណួរអារម្មណ៍ និងជំនឿរបស់ពួកគេប្រកបដោយការគិតគូរ ។

១៥. បង្រៀន និងថ្លែងទីបន្ទាល់អំពីសេចក្តីពិតនៃដំណឹងល្អ ៖ចែកចាយនូវការបង្រៀនដែលអនុវត្តចេញមកពីបទគម្ពីរ និងការបង្រៀនរបស់ពួកព្យាការីបច្ចុប្បន្ន និងពីរបៀបដែលការបង្រៀនបានធ្វើឲ្យមានភាពខុសប្លែកនៅក្នុងជីវិតរបស់អ្នក ។ ជួយដល់អ្នកទាំងឡាយដែលអ្នកនិយាយជាមួយឲ្យពិនិត្យ ឬព្រាងសំណួររបស់ពួកគេសារជាថ្មីនៅក្នុងបរិបទនៃដំណឹងល្អ និងផែនការនៃសេចក្តីសង្គ្រោះ ។

១៦. អញ្ជើញពួកគេឲ្យធ្វើសកម្មភាពដោយសេចក្តីជំនឿ ៖សូមចងចាំថា ព្រះអម្ចាស់តម្រូវឲ្យយើងស្វែងរកចំណេះដឹងខាងវិញ្ញាណសម្រាប់ខ្លួនយើងផ្ទាល់ ។ ហេតុដូច្នោះហើយ យើងត្រូវតែអញ្ជើញអ្នកដទៃឲ្យធ្វើសកម្មភាពដោយសេចក្តីជំនឿ តាមរយៈការអធិស្ឋាន ការគោរពតាមបទបញ្ញត្តិទាំងឡាយ និងការសិក្សាព្រះបន្ទូលនៃព្រះដោយឧស្សាហ៍ព្យាយាម ការប្រើប្រភពដែលបានតែងតាំងដោយព្រះ ជាពិសេសព្រះគម្ពីរមរមន ។ បើអាចធ្វើទៅបាន សូមអញ្ជើញពួកគេឲ្យចងចាំបទពិសោធន៍ដែលពួកគេបានមាន ពេលពួកគេបានទទួលអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធ និងដើម្បីកាន់ខ្ជាប់ទៅនឹងសេចក្តីពិតដ៏អស់កល្បជានិច្ចដែលពួកគេបានរៀនរហូតដល់ចំណេះដឹងបន្ថែមទៀតមកដល់ ។

១៧. បញ្ចប់ ៖ផ្តល់ជំនួយដើម្បីស្វែងរកចម្លើយ បន្ទាប់មកបញ្ចប់ដោយការចែកចាយនូវអ្វីដែលអ្នកបានរៀន ។ អ្នកក៏អាចស្វែងរកចម្លើយជាមួយគ្នាផងដែរ ។ បង្ហាញនូវការទុកចិត្តទៅលើការសន្យារបស់ព្រះអម្ចាស់ដើម្បីប្រទានវិវរណៈផ្ទាល់ខ្លួន ។

សេចក្តីយោងដែលទាក់ទង ៖យេរេមា ១:៤–៥, អេម៉ុស ៣:៧, ម៉ាថាយ ៥:១៤–១៦, ម៉ាថាយ ១៦:១៥–១៩, យ៉ូហាន ១៥:១៦, យ៉ូហាន ១៧:៣, អេភេសូរ ២:១៩–២០, អេភេសូរ ៤:១១–១៤, នីហ្វៃទី ២ ២:២៧, ម៉ូសាយ ១៨:៨–១០, នីហ្វៃទី ៣ ១៨:១៥, ២០–២១, គ. និង ស. ១:៣៧–៣៨, គ. និង ស. ១៨:១៥–១៦, គ. និង ស. ២១:៤–៦,គ. និង ស. ៨៨:១១៨

ប្រធានបទដែលទាក់ទងនឹងគោលលទ្ធិ ៖ ក្រុមព្រះ ៖ ព្រះវិញ្ញាណបរិសុទ្ធ ដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ៖ សេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ ពួកព្យាការី និងវិវរណៈ បទបញ្ញត្តិទាំងឡាយ

# ប្រធានបទនៃគោលលទ្ធិ

ប្រធានបទនៃគោលលទ្ធិទាំងប្រាំបួនខាងក្រោមនេះ រួមបញ្ចូលនូវសេចក្ដីពិតគ្រឹះនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។ សម្រាប់ព័ត៌មានបន្ថែមអំពីប្រធានបទទាំងនេះ សូមចូលទៅគេហទំព័រtopics.lds.org ឬសូមមើលកូនសៀវភៅ ពិតចំពោះសេចក្ដីជំនឿ ៖ ឯកសារយោងនៃដំណឹងល្អ ( ឆ្នាំ ២០០៤ ) ។

# ១. ក្រុមព្រះ



១.១. មានតួអង្គបីអង្គ ដែលមានរូបអង្គដាច់ដោយឡែកពីគ្នានៅក្នុងក្រុមព្រះ ៖ ព្រះជាព្រះវរបិតាដ៏អស់កល្ប ព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ និង ព្រះវិញ្ញាណបរិសុទ្ធ ។ ព្រះវរបិតា និង ព្រះរាជបុត្រាមាននូវរូបកាយជាសាច់ និង ឆ្អឹងដ៏រុងរឿង ហើយរូបិយ ហើយឯព្រះវិញ្ញាណបរិសុទ្ធគឺជាតួអង្គនៃវិញ្ញាណ ( សូមមើល គ. និង ស. ១៣០:២២–២៣ ) ។ ពួកទ្រង់មានព្រះទ័យតែមួយ ហើយរួមសាមគ្គីគ្នាដ៏ឥតខ្ចោះក្នុងការនាំមកនូវផែនការនៃសេចក្ដីសង្គ្រោះរបស់ព្រះវរបិតា ។

សេចក្តីយោងដែលទាក់ទង ៖ លោកុប្បត្តិ ១:២៦–២៧, លូកា ២៤:៣៦–៣៩,យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១៥–២០

## ព្រះជាព្រះវរបិតា

១.២. ព្រះជាព្រះវរបិតាគឺជាព្រះដ៏ខ្ពស់បំផុតដែលយើងថ្វាយបង្គំ ។ ទ្រង់គឺជាបិតានៃវិញ្ញាណរបស់យើង ( សូមមើល ហេព្រើរ ១២:៩) ។ ទ្រង់ល្អឥតខ្ចោះមានគ្រប់ទាំងព្រះចេស្ដា និងជ្រាបនូវគ្រប់ការណ៍ទាំងអស់ ។ ទ្រង់មានយុត្តិធម៌ ប្រកបដោយក្ដីមេត្តាករុណា និងមានព្រះទ័យល្អផងដែរ ។ ព្រះស្រឡាញ់កូនចៅរបស់ទ្រង់ម្នាក់ៗយ៉ាងឥតខ្ចោះ ហើយមនុស្សទាំងអស់គឺស្មើគ្នាចំពោះទ្រង់ ( សូមមើលនីហ្វៃទី ២ ២៦:៣៣ ) ។ កិច្ចការ និងសិរីល្អរបស់ទ្រង់គឺដើម្បីនាំឲ្យមានអមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស ។

សេចក្តីយោងដែលទាក់ទង ៖ យ៉ូហាន ១៧:៣,ម៉ូសាយ ៤:៩,ម៉ូសេ ១:៣៩

## ព្រះយេស៊ូវគ្រីស្ទ

១.៣. ព្រះយេស៊ូវគ្រីស្ទគឺជាបុត្រច្បងខាងវិញ្ញាណរបស់ព្រះវរបិតា ហើយជាបុត្រាបង្កើតតែមួយគត់របស់ព្រះវរបិតាខាងសាច់ឈាម ។ នៅក្រោមការដឹកនាំរបស់ព្រះបិតា ព្រះយេស៊ូវគ្រីស្ទបានបង្កើតស្ថានសួគ៌ និងផែនដី ។ ទ្រង់គឺជាព្រះយេហូវ៉ានៃព្រះគម្ពីរសញ្ញាចាស់ និង ជាព្រះមែស៊ីនៃគម្ពីរសញ្ញាថ្មី ។

១.៤. ព្រះយេស៊ូវគ្រីស្ទធ្វើតាមព្រះទ័យរបស់ព្រះបិតាគ្រប់ការណ៍ទាំងអស់ ។ ទ្រង់បានរស់នៅក្នុងជីវិតដែលគ្មានអំពើបាប ហើយបានធ្វើដង្វាយធួនជំនួសអំពើបាបរបស់មនុស្សគ្រប់គ្នា ( សូមមើលនីហ្វៃទី ៣ ១១:១០-១១ ) ។ ព្រះជន្មរបស់ទ្រង់គឺជាគំរូដ៏ឥតខ្ចោះអំពីរបៀបដែលយើងត្រូវរស់នៅ ( សូមមើលនីហ្វៃទី ៣ ១២:៤៨ ) ។ ទ្រង់គឺជាបុត្រាច្បងរបស់ព្រះវរបិតាសួគ៌ដែលបានរស់ឡើងវិញ ។ នៅជំនាន់របស់យើង ក៏ដូចជានៅជំនាន់បុរាណដែរ ទ្រង់គង់នៅជាសិរិសារនៃសាសនាចក្ររបស់ទ្រង់ ។ ទ្រង់នឹងយាងមកម្ដងទៀតដោយព្រះចេស្ដា និង ភាព

រុងរឿង ហើយនឹងគ្រងលើផែនដីនេះក្នុងអំឡុងពេលសហស្សវត្សរ៍ ( សូមមើល គ. និង ស. ២៩:១០–១១ ) ។ ទ្រង់នឹងជំនុំជម្រះមនុស្សលោកទាំងអស់ ។

១.៥. ដោយសារតែព្រះយេស៊ូវគ្រីស្ទគឺជាព្រះអង្គសង្គ្រោះ និងជាអង្គសង្រ្គួបសង្រួមរបស់យើងជាមួយនឹងព្រះបិតា នោះរាល់ការអធិស្ឋាន ការប្រសិទ្ធពរ និងពិធីបរិសុទ្ធនៃបព្វជិតភាព គួរតែត្រូវបានធ្វើឡើងនៅក្នុងព្រះនាមរបស់ទ្រង់ ( សូមមើលនីហ្វៃទី ៣ ១៨:១៥, ២០-២១ ) ។

សេចក្ដីយោងដែលទាក់ទង ៖ អេសាយ ៥៣:៣–៥, លូកា ២៤:៣៦–៣៩, កូរិនថូសទី ១ ១៥:២០–២២, វិវរណៈ ២០:១២, អាលម៉ា ៧:១១–១៣, អាលម៉ា ៣៤:៩–១០, ហេលេមិន ៥:១២, មរ៉ូណៃ ៧:៤៥, ៤៧–៤៨, គ. និងស. ១:៣០, គ. និងស. ៦:៣៦, គ. និងស. ១៨:១០–១១, គ. និងស. ១៩:១៦–១៩, គ. និង ស. ៧៦:២២–២៤

ប្រធានបទដែលទាក់ទង ៖ ដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ

# ព្រះវិញ្ញាណបរិសុទ្ធ

១.៦. ព្រះវិញ្ញាណបរិសុទ្ធគឺជាសមាជិកទីបីនៃក្រុមព្រះ ។ ទ្រង់គឺជាតួអង្គនៃវិញ្ញាណ ហើយគ្មានរូបកាយជាសាច់ និង ឆ្អឹងនោះទេ ។ ជាញឹកញាប់ ទ្រង់ត្រូវបានគេស្គាល់ថាជាវិញ្ញាណ ជាព្រះវិញ្ញាណបរិសុទ្ធ ជាព្រះវិញ្ញាណនៃព្រះ ជាព្រះវិញ្ញាណនៃព្រះអម្ចាស់ និង ជាអង្គលួងលោម ។

១.៧. ព្រះវិញ្ញាណបរិសុទ្ធថ្លែងសាក្សីអំពីព្រះវរបិតា និង ព្រះរាជបុត្រា បើកសម្ដែងសេចក្ដីពិតនៃការណ៍គ្រប់យ៉ាង និង ញែកអ្នកទាំងឡាយណាដែលបានប្រែចិត្ត និង ទទួលបុណ្យជ្រមុជទឹកឲ្យបានបរិសុទ្ធ ។ តាមរយៈព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ នោះយើងអាចទទួលបានអំណោយទានខាងវិញ្ញាណ ដែលជាពរជ័យ ឬជាសមត្ថភាពដែលបានប្រទានឲ្យដោយព្រះអម្ចាស់ដើម្បីជាប្រយោជន៍របស់យើង និងដើម្បីជួយយើងឲ្យបម្រើ ហើយប្រទានពរដល់អ្នកដទៃទៀត ។

សេចក្ដីយោងដែលទាក់ទង ៖ យ៉ូហាន ៣:៥, កូរិនថូសទី ១ ២:៥, ៩–១១, នីហ្វៃទី ២ ៣២:៣, នីហ្វៃទី ២ ៣២:៨–៩, ម៉ូសាយ ៣:១៩, ម៉ូសាយ ១៨:៨–១០, នីហ្វៃទី ៣ ២៧:២០, មរ៉ូណៃ ៧:៤៥, ៤៧–៤៨, មរ៉ូណៃ ១០:៤–៥, គ. និង ស. ៨:២–៣, គ. និង ស. ១៣០:២២–២៣

ប្រធានបទដែលទាក់ទង ៖ ការទទួលបានចំណេះដឹងខាងវិញ្ញាណ ពិធីបរិសុទ្ធ និងសេចក្ដីសញ្ញាទាំងឡាយ

# ២. ផែនការនៃសេចក្ដីសង្គ្រោះ



២.១. នៅក្នុងជីវិតមុនផែនដីនេះ ព្រះវរបិតាសួគ៌បានបង្ហាញផែនការមួយ ដើម្បីជួយយើងឲ្យប្រែក្លាយទៅដូចជាទ្រង់ និង ទទួលបានជីវិតអមតៈ និង ជីវិតដ៏នៅអស់កល្បជានិច្ច ( សូមមើល ម៉ូសេ ១:៣៩ ) ។ ដើម្បីបំពេញផែនការនេះ ហើយប្រែក្លាយដូចជាព្រះវរបិតាសួគ៌របស់យើង នោះយើងត្រូវតែមកស្គាល់ទ្រង់ និង ព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ហើយយល់ដឹងបានត្រឹមត្រូវអំពីលក្ខណៈសម្បត្តិ និងអាកប្បកិរិយារបស់ពួកទ្រង់ ( សូមមើលយ៉ូហាន ១៧:៣) ។

២.២. ព្រះគម្ពីរជាច្រើនបាននិយាយអំពីផែនការរបស់ព្រះវរបិតាសួគ៌ថាជាផែនការនៃសេចក្ដីសង្គ្រោះ ផែនការនៃសុភមង្គលដ៏មហិមា ផែនការនៃការប្រោសលោះ និង ផែនការនៃក្ដីមេត្តាករុណា ។ ផែនការនេះរួមមាន ការបង្កបង្កើត ការធ្លាក់ដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ និង ក្រឹត្យវិន័យទាំងអស់ ពិធីបរិសុទ្ធទាំងឡាយ និង គោលលទ្ធិទាំងឡាយនៃដំណឹងល្អ ។ សិទ្ធិជ្រើសរើសខាងសីលធម៌—ដែលជាលទ្ធភាពដើម្បីជ្រើសរើស និង ប្រព្រឹត្តដោយខ្លួនយើងផ្ទាល់— គឺជាផ្នែកដ៏សំខាន់នៅក្នុងផែនការនៃព្រះវរបិតាសួគ៌ផងដែរ ។ ការរីកចម្រើនដ៏អស់កល្បជានិច្ចរបស់យើងអាស្រ័យទៅលើរបៀបដែលយើងប្រើអំណោយនេះ ( សូមមើលយ៉ូស្វេ ២៤:១៥នីហ្វៃទី ២ ២:២៧ ) ។

២.៣. ព្រះយេស៊ូវគ្រីស្ទ គឺជាចំនុចសំខាន់នៅក្នុងផែនការនៃព្រះវរបិតាសួគ៌ ។ ផែនការនៃសេចក្ដីសង្គ្រោះ អាចជួយឲ្យយើងបានប្រែក្លាយជាល្អឥតខ្ចោះ ទទួលបានអំណរពេញលេញ រីករាយក្នុងទំនាក់ទំនងគ្រួសាររបស់យើងដល់ភាពអស់កល្បជានិច្ច ហើយរស់នៅជារៀងរហូតក្នុងវត្តមានរបស់ព្រះ ។

សេចក្ដីយោងដែលទាក់ទង ៖ម៉ាទ្បាគី ៤:៥–៦,នីហ្វៃទី ៣ ១២:៤៨,គ. និងស. ១៣១:១–៤

## ជីវិតមុនឆាកជីវិតនេះ

២.៤. ពីមុនយើងបានកើតមកលើផែនដីនេះ យើងបានរស់នៅក្នុងវត្តមាននៃព្រះវរបិតាសួគ៌របស់យើង ក្នុងនាមជាកូនចៅវិញ្ញាណរបស់ទ្រង់ ( សូមមើល អ័ប្រាហាំ ៣:២២–២៣ ) ។ នៅក្នុងជីវិតមុនផែនដី យើងបានចូលរួមនៅក្នុងក្រុមប្រឹក្សាមួយជាមួយនឹងកូនចៅវិញ្ញាណផ្សេងទៀតរបស់ព្រះវរបិតាសួគ៌ ។ ក្នុងអំឡុងពេលប្រជុំក្រុមប្រឹក្សានោះ ព្រះវរបិតាសួគ៌បានបង្ហាញដល់យើងនូវផែនការរបស់ទ្រង់ ហើយព្រះយេស៊ូវគ្រីស្ទពីមុនជីវិតលើផែនដីនេះបានធ្វើសេចក្ដីសញ្ញាដើម្បីធ្វើជាអង្គសង្គ្រោះ ។

២.៥. យើងបានប្រើប្រាស់សិទ្ធិជ្រើសរើសរបស់យើង ដើម្បីធ្វើតាមផែនការព្រះវរបិតាសួគ៌ ។ អស់អ្នកណាដែលបានធ្វើតាមព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទត្រូវបានអនុញ្ញាតឲ្យមកកាន់ផែនដីនេះ ដើម្បីទទួលបានបទពិសោធន៍នៃជីវិតរមែងស្លាប់ និង រីកចម្រើនទៅរកជីវិតដ៏នៅអស់កល្ប

ជានិច្ច ។ លូស៊ីហ្វើរ ជាកូនវិញ្ញាណនៃព្រះម្នាក់ទៀត ដែលបានជំទាស់ប្រឆាំងនឹងផែនការនេះ ។ វាបានក្លាយទៅជាសាតាំង ហើយវា និងពួកពលបរិវារទាំងឡាយរបស់វាត្រូវបានបណ្តេញចេញពីស្ថានសួគ៌ ហើយមិនបានទទួលឯកសិទ្ធិនៃការទទួលបានរូបកាយ និង បទពិសោធន៍នៃជីវិតរមែងស្លាប់ឡើយ ។

សេចក្ដីយោងដែលទាក់ទង ៖ យេរេមា ១:៤-៥,ហេព្រើរ ១២:៩,នីហ្វៃទី ២ ២:២៧នីហ្វៃទី ៣ ១១:១០-១១

## ការបង្កបង្កើត

២.៦. ព្រះយេស៊ូវគ្រីស្ទបានបង្កើតស្ថានសួគ៌ និង ផែនដីក្រោមការដឹកនាំរបស់ព្រះវរបិតា ( សូមមើល គ. និង ស. ៧៦:២២-២៤) ។ ការបង្កើតផែនដីគឺជាផ្នែកមួយដ៏សំខាន់នៃផែនការរបស់ព្រះ ។ ផែនដីផ្តល់ឲ្យយើងនូវកន្លែងដែលយើងអាចទទួលបានរូបកាយ ត្រូវបានសាកល្បង និង ទទួលបទពិសោធន៍ព្រមទាំងអភិវឌ្ឍនូវគុណធម៌ទេវភាព ។

២.៧. អ័ដាមគឺជាមនុស្សដំបូងគេ ដែលត្រូវបានបង្កើតនៅលើផែនដីនេះ ។ ព្រះបានបង្កើត អ័ដាម និង អេវ៉ា តាមរូបរាងរបស់អង្គទ្រង់ផ្ទាល់ ។ គ្រប់មនុស្សលោកទាំងអស់—ប្រុស និង ស្រី—ត្រូវបានបង្កើតតាមរូបរាងរបស់ព្រះ ( សូមមើល លោកុប្បត្តិ ១:២៦-២៧ ) ។ ភេទប្រុសស្រី គឺជាលក្ខណៈពិសេសនៃអត្តសញ្ញាណ និង គោលបំណងរបស់មនុស្សម្នាក់ៗនៅក្នុងជីវិតមុនផែនដី ជីវិតរមែងស្លាប់ និង ជីវិតដ៏នៅអស់កល្បជានិច្ច ។

## ការធ្លាក់

២.៨. នៅក្នុងសួនច្បារអេដែន ព្រះបានរៀបការអ័ដាម និងនាងអេវ៉ា ។ ខណៈដែលអ័ដាម និងនាងអេវ៉ាស្ថិតនៅក្នុងសួនច្បារនៅឡើយ នោះពួកគេនៅតែស្ថិតនៅក្នុងវត្តមានរបស់ព្រះ ហើយអាចរស់នៅជារៀងរហូតបាន ។ ពួកគេរស់នៅក្នុងភាពស្លូតត្រង់ ហើយព្រះបានប្រទានគ្រប់តម្រូវការរបស់ពួកគេ ។

២.៩. ព្រះបានប្រទានដល់អ័ដាម និងនាងអេវ៉ានូវសិទ្ធិជ្រើសរើស ខណៈដែលពួកគេស្ថិតនៅក្នុងសួនច្បារអេដែន ។ ទ្រង់បានបញ្ជាពួកគេមិនឲ្យបរិភោគផ្លែឈើហាមឃាត់—ជាផ្លែឈើនៃដើមឈើសម្រាប់ដឹងខុសត្រូវឡើយ ។ ការគោរពតាមបទបញ្ញត្តិនេះ មានន័យថាពួកគេអាចបន្តរស់នៅក្នុងសួនច្បារ ។ ទោះជាយ៉ាងណាក៏ដោយ អ័ដាម និងនាងអេវ៉ាពុំទាន់បានយល់នៅឡើយទេថាប្រសិនបើពួកគេបន្តនៅក្នុងសួនច្បារ នោះពួកគេពុំអាចរីកចម្រើនតាមរយៈការទទួលបទពិសោធន៍នូវការផ្ទុយនៅក្នុងជីវិតរមែងស្លាប់ឡើយ ។ ពួកគេមិនអាចស្គាល់ភាពរីករាយ ព្រោះតែពួកគេមិនអាចមានបទពិសោធន៍នៃការសោកសៅ និងការឈឺចាប់ ។ លើសពីនោះទៅទៀត ពួកគេពុំអាចមានកូនចៅបានឡើយ ។

២.១០. សាតាំងបានល្បួងអ័ដាម និងនាងអេវ៉ាឲ្យទទួលទានផ្លែឈើហាមឃាត់ ហើយពួកគេបានជ្រើសរើសធ្វើដូច្នោះ ។ ដោយសារតែការជ្រើសរើសនេះ នោះពួកគេត្រូវបានបណ្តេញចេញពីវត្តមានរបស់ព្រះ ហើយបានធ្លាក់ចុះ និងមានជីវិតរមែងស្លាប់ ។ ការរំលងរបស់អ័ដាម និង នាងអេវ៉ា ព្រមទាំងលទ្ធផលនៃការផ្លាស់ប្ដូរដែលពួកគេបានដកពិសោធន៍ រួមទាំងសេចក្តីស្លាប់ខាងវិញ្ញាណ និងសេចក្តីស្លាប់ខាងរូបកាយ គឺត្រូវបានហៅថាការធ្លាក់ ។ សេចក្តីស្លាប់ខាងវិញ្ញាណគឺជាការបែកចេញពីព្រះ ។ សេចក្តីស្លាប់ខាងរូបកាយគឺជាការបែកចេញរវាងវិញ្ញាណ និងរូបកាយរមែងស្លាប់ ។

២.១១. ការធ្លាក់គឺជាផ្នែកមួយដ៏សំខាន់នៃផែនការនៃសេចក្តីសង្គ្រោះរបស់ព្រះវរបិតាសួគ៌ ។ ជាលទ្ធផលនៃការធ្លាក់ នោះអ័ដាម និងនាងអេវ៉ាអាចបង្កើតកូនចៅបាន ។ ពួកគេ និងកូនចៅរបស់ពួកគេ អាចទទួលបទពិសោធន៍នៃសេចក្តីអំណរ និងទុក្ខព្រួយ ដឹងល្អ ដឹងអាក្រក់ ហើយរីកចម្រើន ( សូមមើលនីហ្វៃទី ២ ២:២២-២៥ ) ។

២.១២. ក្នុងនាមជាកូនចៅរបស់អ័ដាម និង នាងអេវ៉ា នោះយើងទទួលបាននូវលក្ខខណ្ឌនៃការធ្លាក់ក្នុងអំឡុងពេលជីវិតរមែងស្លាប់នេះ ។ យើងត្រូវបានបំបែកចេញពីវត្តមានរបស់ព្រះ ហើយស្ថិតនៅក្រោមឥទ្ធិពលនៃសេចក្តីស្លាប់ខាងរូបកាយ ។ យើងក៏ត្រូវបានសាកល្បងដោយភាពលំបាកនៃជីវិត និង ការល្បួងពីមារសត្រូវផងដែរ ។ ខណៈដែលយើងមិនទទួលខុសត្រូវចំពោះអំពើរំលងរបស់អ័ដាម និងនាងអេវ៉ា នោះយើងមានការទទួលខុសត្រូវចំពោះអំពើបាបផ្ទាល់ខ្លួនរបស់យើង ។ តាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ នោះយើងអាចយកឈ្នះលើឥទ្ធិពលអវិជ្ជមាននៃការធ្លាក់ ទទួលការអភ័យទោសចំពោះអំពើបាបរបស់យើង ហើយទីបំផុតទទួលបានបទពិសោធន៍នៃអំណរដ៏ពេញលេញ ។

សេចក្ដីយោងដែលទាក់ទង ៖លោកុប្បត្តិ ១:២៨,ម៉ូសាយ ៣:១៩,អាលម៉ា ៣៤:៩-១០

ប្រធានបទដែលទាក់ទង ៖ ដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ

## ជីវិតរមែងស្លាប់

២.១៣. ជីវិតរមែងស្លាប់គឺជាពេលវេលាមួយនៃការរៀនសូត្រ ដែលអំឡុងពេលនេះយើងបង្ហាញថាយើងនឹងប្រើសិទ្ធិសេរីភាពរបស់យើងដើម្បីធ្វើអ្វីៗទាំងអស់ដែលព្រះអម្ចាស់បានបញ្ជា ហើយរៀបចំខ្លួនសម្រាប់ជីវិតដ៏អស់កល្បជានិច្ចដោយការអភិវឌ្ឍលក្ខណៈដូចព្រះ ។ យើងធ្វើដូចនេះ នៅពេលយើងអនុវត្តសេចក្ដីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ និងដង្វាយធួនរបស់ ទ្រង់ ប្រែចិត្ត ទទួលពិធីបរិសុទ្ធ និងសេចក្តីសញ្ញានៃការសង្គ្រោះ ដូចជាពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ ហើយប្រកាន់ខ្ជាប់ដោយស្មោះត្រង់ដល់ចុងបំផុតនៃជីវិតរមែងស្លាប់របស់យើងដើម្បីដើរតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទ ។

២.១៤. នៅក្នុងជីវិតរមែងស្លាប់ វិញ្ញាណរបស់យើងត្រូវបានរួមគ្នាជាមួយនឹងរូបកាយរបស់យើង ដែលការណ៍នេះផ្តល់ឲ្យយើងនូវឱកាសដើម្បីរីកចម្រើន និងអភិវឌ្ឍតាមវិធីជាច្រើនដែលមិនអាចកើតមានបាននៅក្នុងជីវិតមុនផែនដី ។ ដោយសារតែព្រះវរបិតាដែលគង់នៅស្ថានសួគ៌របស់យើង មានរូបកាយសាច់ និងឆ្អឹង នោះរូបកាយរបស់យើងគឺចាំបាច់សម្រាប់ឲ្យយើងរីកចម្រើន ហើយប្រែក្លាយដូចជាទ្រង់ ។ រូបកាយរបស់យើងគឺពិសិដ្ឋ ហើយគួរតែត្រូវបានគោរពថាជាអំណោយមួយមកពីព្រះវរបិតាសួគ៌របស់យើង ( សូមមើល កូរិនថូសទី ១ ៦:១៩-២០

សេចក្ដីយោងដែលទាក់ទង ៖ យ៉ូស្វេ ២៤:១៥, ម៉ាថាយ ២២:៣៦-៣៩, យ៉ូហាន ១៤:១៥, នីហ្វៃទី ២ ២:២៧, នីហ្វៃទី ៣ ១២:៤៨, ម៉ូរ៉ូណៃ ៧:៤៥, ៤៧-៤៨, គ. និង ស. ១៣០:២២-២៣

ប្រធានបទដែលទាក់ទង ៖ ក្រុមព្រះដ ង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ពិធីបរិសុទ្ធ និងសេចក្ដីសញ្ញា បទបញ្ញត្តិទាំងឡាយ

## ជីវិតក្រោយសេចក្តីស្លាប់

២.១៥. នៅពេលយើងស្លាប់ វិញ្ញាណរបស់យើងចូលទៅក្នុងពិភពវិញ្ញាណ ហើយរង់ចាំការរស់ឡើងវិញ ។ វិញ្ញាណនៃពួកសុចរិតត្រូវបានទទួលស្ថានភាពនៃសុភមង្គល ដែលត្រូវបានហៅថាស្ថានបរមសុខ ។ អស់អ្នកទាំងឡាយដែលបានស្លាប់ទៅដោយមិន បានទទួលចំណេះដឹងនៃសេចក្តីពិត និងអស់អ្នកដែលមិនបានគោរពប្រតិបត្តិតាមនៅក្នុងជីវិតរមែងស្លាប់នឹងចូលទៅកន្លែងបណ្តោះអាសន្នមួយក្នុងពិភពវិញ្ញាណក្រោយពីជីវិតរមែងស្លាប់ ដែលហៅថាស្ថានឃុំព្រលឹង ។

២.១៦. ទីបំផុតមនុស្សគ្រប់រូបនឹងមានឱកាសរៀនពីគោលការណ៍នៃដំណឹងល្អ ហើយទទួលបានពិធីបរិសុទ្ធ និងសេចក្តីសញ្ញាទាំងឡាយ។ មានពួកអ្នកស្មោះត្រង់

ជាច្រើននឹងផ្សាយដំណឹងល្អទៅកាន់អ្នកទាំងនោះនៅក្នុងស្ថានឃុំព្រលឹង ។ អស់អ្នកដែលបានជ្រើសរើសទទួលយកដំណឹងល្អ ប្រែចិត្ត ហើយទទួលពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះ ដែលត្រូវបានធ្វើឡើងសម្រាប់ពួកគេនៅក្នុងព្រះវិហារបរិសុទ្ធ នឹងរស់នៅក្នុងស្ថានបរមសុខរហូតដល់ការរស់ឡើងវិញ ( សូមមើលពេត្រុសទី ១ ៤:៦ ) ។

២.១៧. ការរស់ឡើងវិញគឺជាការរួមបញ្ចូលគ្នាវិញនៃរូបកាយជាវិញ្ញាណរបស់យើងជាមួយនឹងរូបកាយជាសាច់ និង ឆ្អឹងរបស់យើង ។ បន្ទាប់ពីការរស់ឡើងវិញនោះយើងនឹងមានរូបកាយអមត—វិញ្ញាណ និងរូបកាយរបស់យើងនឹងពុំបែកចេញពីគ្នាទៀតឡើយ ។ មនុស្សគ្រប់រូបដែលកើតមកលើផែនដីនឹងត្រូវបានរស់ឡើងវិញ ពីព្រោះព្រះយេស៊ូវគ្រីស្ទបានយកឈ្នះលើសេចក្ដីស្លាប់ខាងរូបកាយ ( សូមមើល កូរិនថូសទី ១ ១៥:២០–២២ ) ។ ពួកសុចរិតនឹងរស់ឡើងវិញមុនពួកទុច្ចរិត ហើយពួកគេរស់ឡើងវិញនៅក្នុងដំណើររស់ឡើងវិញទីមួយ ។

២.១៨. សេចក្ដីជំនុំជម្រះចុងក្រោយនឹងកើតឡើងបន្ទាប់ពីការរស់ឡើងវិញ ។ ព្រះយេស៊ូវគ្រីស្ទនឹងកាត់សេចក្ដីមនុស្សគ្រប់រូប ដើម្បីកំណត់នូវសេចក្ដីរុងរឿងដ៏អស់កល្បដែលបុគ្គលនោះនឹងទទួលបាន ។ ការកាត់សេចក្ដីនេះនឹងផ្អែកទៅលើបំណងប្រាថ្នា និងការគោរពប្រតិបត្តិតាមព្រះបញ្ញត្តិរបស់ព្រះរបស់បុគ្គលម្នាក់ៗ ( សូមមើល វិវរណៈ ២០:១២ ) ។

២.១៩. មាននគរនៃសិរីល្អចំនួនបីគឺ ៖ នគរសេឡេស្ទាល នគរទេរេស្ទ្រាល និងនគរទេឡេស្ទាល ( សូមមើលកូរិនថូសទី ១ ១៥:៤០-៤២ ) ។ អ្នកទាំងឡាយណាដែលមានសេចក្ដីក្លាហាននៅក្នុងការថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ និងគោរពប្រតិបត្តិតាមគោលការណ៍ទាំងឡាយនៃដំណឹងល្អនឹងរស់នៅក្នុងនគរសេឡេស្ទាលក្នុងវត្តមាននៃព្រះវរបិតា និង ព្រះរាជបុត្រាទ្រង់ គឺ ព្រះយេស៊ូវគ្រីស្ទ និងនៅជាមួយសមាជិកគ្រួសារដ៏សុចរិតរបស់ពួកគេទាំងឡាយ ។

សេចក្ដីយោងដែលទាក់ទង ៖ លូកា ២៤:៣៦–៣៩, យ៉ូហាន ១៧:៣, គ. និង ស. ១៣១:១–៤

ប្រធានបទដែលទាក់ទង ៖ ដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ពិធីបរិសុទ្ធ និងសេចក្ដីសញ្ញាទាំងឡាយ

# ៣. ដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ



៣.១. ព្រះយេស៊ូវគ្រីស្ទ ត្រូវបានតែងតាំងពីមុនកំណើតលោកិយនៅក្នុងក្រុមប្រឹក្សាពីមុនជីវិតនេះ ដើម្បីធ្វើជាព្រះអង្គសង្គ្រោះ និងព្រះប្រោសលោះរបស់យើង ។ ទ្រង់បានយាងមកលើផែនដី ហើយស្ម័គ្រព្រះទ័យរងទុក្ខ និងសុគតដើម្បីប្រោសលោះមនុស្សលោកទាំងអស់គ្នាឲ្យផុតពីឥទ្ធិពលអវិជ្ជមាននៃការធ្លាក់ និងដើម្បីបង់ថ្លៃអំពើបាបទាំងឡាយរបស់យើង ។ ជោគជ័យរបស់ព្រះយេស៊ូវគ្រីស្ទក្នុងការយកឈ្នះលើសេចក្ដីស្លាប់ខាងវិញ្ញាណ និងខាងរូបកាយដោយការរងទុក្ខ ការសុគត និងការរស់ឡើងវិញរបស់ទ្រង់ គឺត្រូវបានហៅថាដង្វាយធួន ។ ពលិកម្មរបស់ទ្រង់មានប្រយោជន៍ដល់យើងម្នាក់ៗ ហើយបង្ហាញនូវតម្លៃដ៏គ្មានទីបំផុតរបស់កូនម្នាក់ៗរបស់ព្រះវរបិតាសួគ៌ ( សូមមើលគ. និង ស. ១៨:១០-១១ ) ។

៣.២. វាមានតែតាមរយៈព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះ ដែលយើងអាចត្រូវបានសង្គ្រោះ ដោយសារទ្រង់គឺជាអង្គតែមួយគត់ដែលអាចធ្វើដង្វាយធួនដ៏និរន្តរ៍ និងអស់កល្បជានិច្ចនេះសម្រាប់មនុស្សលោកបាន ( សូមមើលអាលម៉ា ៣៤:៩-១០ ) ។ មានតែទ្រង់មួយអង្គគត់ដែលមានព្រះចេស្ដាយកឈ្នះលើសេចក្ដីស្លាប់ខាងរូបកាយ ។ ចេញពីមាតាខាងជីវិតរមែងស្លាប់របស់ទ្រង់ នោះទ្រង់ទទួលបាននូវលទ្ធភាពដើម្បីសុគត ។ ចេញពីព្រះ ជាព្រះបិតាអមតរបស់ទ្រង់ នោះទ្រង់បានទទួលមរតកនូវអំណាចដើម្បីរស់នៅជារៀងរហូត ឬដាក់ជីវិតទ្រង់ចុះ ហើយអាចយកវាមកវិញបាន ។ ទ្រង់តែមួយអង្គឯង អាចប្រោសលោះយើងចេញពីអំពើបាបរបស់យើងបាន ។ ដោយសារទ្រង់បានរស់នៅជីវិតដ៏ឥតខ្ចោះ និងគ្មានអំពើបាប នោះទ្រង់មានសេរីភាពពីការទាមទារនៃសេចក្ដីយុត្តិធម៌ ហើយអាចបង់ថ្លៃបំណុលសម្រាប់អ្នកទាំងឡាយដែលប្រែចិត្ត ។

៣.៣. ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ មានរួមទាំងការរងទុក្ខរបស់ទ្រង់សម្រាប់អំពើបាបនៃមនុស្សលោកនៅក្នុងសួនច្បារគេតសេម៉ានី ការបង្ហូរលោហិតរបស់ទ្រង់ ការរងទុក្ខ និងការសុគតនៅលើឈើឆ្កាងរបស់ទ្រង់ ហើយនឹងការរស់ឡើងវិញរបស់ទ្រង់ ។ ទ្រង់គឺជាផលដំបូងដែលបានរស់ឡើងវិញ ។ ទ្រង់បានរស់ឡើងវិញចេញពីផ្នូរដោយសិរីរុងរឿង មានរូបកាយជាសាច់ និងឆ្អឹងដ៏អមត ( សូមមើលលូកា ២៤:៣៦-៣៩ ) ។ ដោយសារតែដង្វាយធួនរបស់ទ្រង់ នោះមនុស្សលោកគ្រប់រូបនឹងបានរស់ឡើងវិញដោយមានរូបកាយឥតខ្ចោះ អមត ហើយអាចត្រូវបាននាំត្រឡប់ទៅកាន់វត្តមានរបស់ព្រះដើម្បីជំនុំជំរះ ។ ពលិកម្មដ៏ធួនរបស់ព្រះយេស៊ូវគ្រីស្ទ បានផ្ដល់ជាមធ្យោបាយតែមួយគត់សម្រាប់យើងដើម្បីអាចត្រូវបានសម្អាត និងអភ័យទោសពីអំពើបាបរបស់យើង ដើម្បីយើងអាចរស់នៅក្នុងវត្តមានរបស់ព្រះដ៏នៅអស់កល្បជានិច្ចបាន ( សូមមើលអេសាយ ១:១៨,គ. និង ស. ១៩:១៦-១៩ ) ។

៣.៤. ជាចំណែកនៃដង្វាយធួនរបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទមិនត្រឹមតែរងទុក្ខសម្រាប់អំពើបាបរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ថែមទាំងបានលើកមកដាក់លើព្រះអង្គទ្រង់នូវការឈឺចាប់ ការល្បួង ជំងឺ និង រោគាទាំងឡាយរបស់មនុស្សទៀតផង ( សូមមើលអេសាយ ៥៣:៣–៥,អាលម៉ា ៧:១១–១៣ ) ។ ទ្រង់យល់អំពីការឈឺចាប់របស់យើង ពីព្រោះទ្រង់បានទទួលនូវបទពិសោធន៍នៃការឈឺចាប់

នោះ ។ នៅពេលយើងមករកទ្រង់ដោយសេចក្តីជំនឿ នោះព្រះអង្គសង្គ្រោះនឹងពង្រឹងយើងដើម្បីរែកបន្ទុក ហើយសម្រេចកិច្ចការដែលយើងមិនអាចធ្វើដោយខ្លួនយើងបាន ( សូមមើលម៉ាថាយ ១១:២៨-៣០,អេធើរ ១២:២៧ ) ។

៣.៥. ការទទួលទោសជំនួសអំពើបាបរបស់យើង ពុំមែនមានន័យថា ព្រះយេស៊ូវគ្រីស្ទដកយកការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់យើងនោះទេ ។ ដើម្បីទទួលបានពលិកម្មរបស់ទ្រង់ ដើម្បីត្រូវបានសម្អាតចេញពីអំពើបាបរបស់យើង ហើយទទួលគ្រងជីវិតអស់កល្បជានិច្ច នោះយើងត្រូវតែអនុវត្តសេចក្តីជំនឿទៅលើទ្រង់ ប្រែចិត្ត ទទួលបុណ្យជ្រមុជទឹក ទទួលព្រះវិញ្ញាណបរិសុទ្ធ ហើយប្រកាន់ខ្ជាប់ដោយស្មោះត្រង់ដល់ចុងបំផុតនៃជីវិតរបស់យើង ។

សេចក្តីយោងដែលទាក់ទង ៖ យ៉ូហាន ៣:៥, កូរិនថូសទី ១ ១៥:២០–២២, ម៉ូសាយ ៣:១៩, នីហ្វៃទី ៣ ១១:១០–១១, នីហ្វៃទី ៣ ២៧:២០, គ. និង ស. ៧៦:២២–២៤

ប្រធានបទដែលទាក់ទង ៖ ក្រុមព្រះ ៖ ព្រះយេស៊ូវគ្រីស្ទ ផែនការនៃសេចក្តីសង្គ្រោះ ៖ ការធ្លាក់ ពិធីបរិសុទ្ធ និងសេចក្តីសញ្ញាទាំងឡាយ

## សេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ

៣.៦. គោលការណ៍ទីមួយនៃដំណឹងល្អគឺសេចក្តីជំនឿទៅលើព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ។ សេចក្តីជំនឿរបស់យើងអាចដឹកនាំទៅរកសេចក្តីសង្គ្រោះ តែនៅពេលដែលវាផ្តោតទៅលើព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះ ( សូមមើលហេលេមិន ៥:១២ ) ។

៣.៧. ការមានសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ រួមបញ្ចូលនូវការមានជំនឿរឹងមាំថា ទ្រង់គឺជាព្រះរាជបុត្រាសំណព្វតែមួយគត់របស់ព្រះ និងជាព្រះអង្គសង្គ្រោះនៃពិភពលោក ។ យើងទទួលស្គាល់ថា មធ្យោបាយតែមួយគត់ដែលយើងអាចត្រឡប់ទៅរស់នៅជាមួយព្រះវរបិតាសួគ៌របស់យើងវិញបាន គឺតាមរយៈការពឹងផ្អែកទៅលើដង្វាយធួនជានិរន្តរ៍របស់ព្រះរាជបុត្រាទ្រង់ និងតាមរយៈការទុកចិត្តទៅលើព្រះយេស៊ូវគ្រីស្ទ និងការធ្វើតាមការបង្រៀនទាំងឡាយរបស់ទ្រង់ ។ លើសពីការទទួលយកនូវការជឿអកម្ម សេចក្តីជំនឿពិតទៅលើព្រះយេស៊ូវគ្រីស្ទនាំទៅរកសកម្មភាព ហើយត្រូវបានបង្ហាញតាមរបៀបដែលយើងរស់នៅ ( សូមមើលយ៉ាកុប ២:១៧-១៨ ) ។ សេចក្តីជំនឿរបស់យើងអាចរីកចម្រើនឡើង នៅពេលយើងអធិស្ឋាន សិក្សាព្រះគម្ពីរ និងគោរពប្រតិបត្តិតាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះ ។

សេចក្តីយោងដែលទាក់ទង ៖ សុភាសិត ៣:៥–៦, អេធើរ ១២:៦, គ. និង ស. ៦:៣៦

ប្រធានបទដែលទាក់ទង ៖ ការទទួលបានចំណេះដឹងខាងវិញ្ញាណ

## ការប្រែចិត្ត

៣.៨. សេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ និងសេចក្តីស្រឡាញ់របស់យើងចំពោះទ្រង់ និងព្រះវរបិតាសួគ៌ ដឹកនាំយើងឲ្យប្រែចិត្ត ។ ការប្រែចិត្តគឺជាចំណែកនៃផែនការរបស់ព្រះវរបិតាសួគ៌ចំពោះកូនចៅទាំងអស់របស់ទ្រង់ ដែលទទួលខុសត្រូវចំពោះការជ្រើសរើសរបស់ពួកគេ ។ អំណោយទាននេះនឹងត្រូវបានធ្វើឲ្យកើតមានឡើង តាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។ ការប្រែចិត្តគឺជាការផ្លាស់ប្តូរមួយក្នុងគំនិត និង ដួងចិត្ត ។ វារួមមានទាំងការងាកចេញពីអំពើបាប និងការបែរគំនិត សកម្មភាព និងបំណងប្រាថ្នារបស់យើងទៅរកព្រះ ហើយសម្របឆន្ទៈរបស់យើងទៅតាមព្រះឆន្ទៈរបស់ទ្រង់ ( សូមមើលម៉ូសាយ ៣:១៩ ) ។

៣.៩. ការប្រែចិត្ត រួមមាននូវការទទួលស្គាល់អំពើបាបរបស់យើង ការមានអារម្មណ៍សោកស្តាយ ឬ សេចក្តីព្រួយដែលគាប់ព្រះហឫទ័យដល់ព្រះចំពោះការប្រព្រឹត្តអំពើបាប ការសារភាពអំពើបាបរបស់យើងទៅកាន់ព្រះវរបិតាសួគ៌ ហើយបើចាំបាច់ សារភាពទៅកាន់អ្នកដទៃទៀត ការលះបង់ចោលអំពើបាប ការស្វែងរកការស្តារឡើងវិញតាមដែលអាចធ្វើទៅបានចំពោះអ្វីៗ ដែលបានខូចខាតដោយសារលទ្ធផលនៃអំពើបាបរបស់យើង និង ការរស់នៅដោយគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះ ( សូមមើល គ. និង ស. ៥៨:៤២–៤៣ ) ។ ព្រះអម្ចាស់សន្យាថានឹងអភ័យទោសដល់អំពើបាបរបស់យើងនៅពិធីបុណ្យជ្រមុជទឹក ហើយយើងរំឭកសេចក្តីសញ្ញានោះនៅគ្រប់ពេលដែលយើងទទួលទានសាក្រាម៉ង់ដោយស្មោះ ដោយបំណងចិត្តចងចាំដល់ព្រះអង្គសង្គ្រោះ និងរក្សាបទបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។

៣.១០. តាមរយៈការប្រែចិត្តដោយស្មោះ និងព្រះគុណដែលបានប្រទានឲ្យតាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ នោះយើងអាចទទួលបានការអភ័យទោសរបស់ព្រះ ហើយមានអារម្មណ៍សុខសាន្ត ។ យើងនឹងទទួលអារម្មណ៍ពីឥទ្ធិពលនៃព្រះវិញ្ញាណយ៉ាងច្រើនសន្ធឹក ហើយយើងកាន់តែត្រៀមខ្លួនដើម្បីរស់នៅអស់កល្បជានិច្ចជាមួយព្រះវរបិតាសួគ៌ និងព្រះរាជបុត្រារបស់ទ្រង់ ។

សេចក្តីយោងដែលទាក់ទង ៖ អេសាយ ១:១៨, យ៉ូហាន ១៤:១៥, នីហ្វៃទី ៣ ២៧:២០, គ. និង ស. ១៩:១៦–១៩

ប្រធានបទដែលទាក់ទង ៖ ពិធីបរិសុទ្ធ និងសេចក្តីសញ្ញាទាំងឡាយ

# ៤. ការស្តារឡើងវិញ



៤.១. ព្រះបានស្តារដំណឹងល្អរបស់ទ្រង់ឡើងវិញនៅថ្ងៃចុងក្រោយទាំងនេះ ដោយការស្តាបនាឡើងវិញនូវសេចក្តីពិតរបស់ទ្រង់ សិទ្ធិអំណាចបព្វជិតភាព និងសាសនាចក្រនៅលើផែនដីនេះ ។ ពួកព្យាការីពីបុរាណទាំងឡាយបានព្យាករអំពីការស្តារឡើងវិញនៃដំណឹងល្អនៅថ្ងៃចុងក្រោយ ( សូមមើលអេសាយ ២៩:១៣-១៤,កិច្ចការ ៣:១៩-២១ ) ។

៤.២. ការស្តារឡើងវិញបានចាប់ផ្តើមនៅឆ្នាំ ១៨២០ ។ ព្រះជាព្រះបិតា និងព្រះរាជបុត្រាទ្រង់គឺព្រះយេស៊ូវគ្រីស្ទ បានបង្ហាញព្រះកាយដល់យ៉ូសែប ស្ម៊ីធ ជាការឆ្លើយតបចំពោះការអធិស្ឋានរបស់យ៉ូសែប ហើយពួកទ្រង់បានហៅលោកឲ្យធ្វើជាព្យាការីនៃការស្តារឡើងវិញ ( សូមមើលយ៉ូសែប ស្ម៊ីធ–ប្រវត្តិ ១:១៥-២០ ) ។

៤.៣. ព្រះបានហៅយ៉ូសែប ស្ម៊ីធ ឲ្យធ្វើជាសាក្សីថ្ងៃចុងក្រោយអំពីព្រះគ្រីស្ទដ៏មានព្រះជន្មរស់ ។ ក្នុងនាមជាព្យាការីនៃការស្តារឡើងវិញ យ៉ូសែប ស្ម៊ីធ បានបកប្រែព្រះគម្ពីរមរមនដោយអំណោយទាន និងព្រះចេស្តានៃព្រះ ( សូមមើលគ. និង ស. ១៣៥:៣ ) ។ ព្រះគម្ពីរមរមនអមជាមួយនឹងព្រះគម្ពីរប៊ីប បានថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ហើយមាននូវភាពពេញលេញនៃដំណឹងល្អ ( សូមមើលអេសេគាល ៣៧:១៥-១៧ ) ។ ព្រះគម្ពីរមរមនក៏ជាសាក្សីអំពីការហៅជាព្យាការីរបស់យ៉ូសែប ស្ម៊ីធ និងភាពពេញលេញនៃការស្តារឡើងវិញផងដែរ ។

៤.៤. ជាចំណែកនៃការស្តារឡើងវិញ ព្រះបានបញ្ជូនសារទូតទេវតាឲ្យមកស្តារបព្វជិតភាពអើរ៉ុន និងបព្វជិតភាពមិលគីស្សាដែកឡើងវិញ ។ បន្ទាប់មក ទ្រង់បានបង្គាប់ថា សាសនាចក្ររបស់ ទ្រង់ត្រូវរៀបចំឡើងជាថ្មីនៅលើផែនដីនៅ ថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៨៣០ ។ ដោយសារសាសនាចក្រត្រូវបានស្តាបនាឡើងពីព្រះផ្ទាល់ នោះសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយគឺជា « សាសនាចក្រតែមួយដែលពិត ហើយសកម្មនៅលើផ្ទៃផែនដីទាំងមូល » ( គ. និង ស. ១:៣០ ) ។

សេចក្តីយោងដែលទាក់ទង ៖ អេម៉ុស ៣:៧, អេភេសូរ ២:១៩–២០, អេភេសូរ ៤:១១–១៤, គ. និង ស. ១៣:១, គ. និង ស. ៧៦:២២–២៤, គ. និង ស. ១០៧:៨

ប្រធានបទដែលទាក់ទង ៖ ក្រុមព្រះ ពួកព្យាការី និងវិវរណៈ

## ការក្បត់សាសនា

៤.៥. តម្រូវការដើម្បីមានការស្តារឡើងវិញនៃសេចក្តីពិតរបស់ព្រះនៅក្នុងថ្ងៃចុងក្រោយនោះគឺ សិទ្ធិអំណាចបព្វជិតភាព ហើយសាសនាចក្របានកើតឡើងវិញដោយសារតែការក្បត់សាសនា ។ ការក្បត់សាសនាកើតឡើងនៅពេលដែលបុគ្គលម្នាក់ ឬច្រើននាក់បានងាកចេញពីសេចក្តីពិតនៃដំណឹងល្អ ។

៤.៦. បន្ទាប់ពីការឆ្កាងរបស់ព្រះអង្គសង្គ្រោះ និងការស្លាប់របស់ពួកសាវករបស់ទ្រង់ នោះមានមនុស្សជាច្រើនបានងាកចេញពីសេចក្តីពិតដែលព្រះអង្គសង្គ្រោះបានស្ថាបនាឡើង ( សូមមើលថែស្សាឡូនិចទី ២ ២:១-៣ ) ។ គោលការណ៍ទាំងឡាយនៃដំណឹងល្អ និងផ្នែកជាច្រើននៃបទគម្ពីរបរិសុទ្ធត្រូវបានបាត់បង់ ឬបំផ្លាញចោល ។ ការផ្លាស់ប្តូរដោយគ្មានសិទ្ធិអំណាចបានធ្វើឡើងនៅក្នុងការរៀបចំសាសនាចក្រ និងពិធីបរិសុទ្ធបព្វជិតភាពនានា ។ ដោយសារការរីករាលដាលនៃភាពទុច្ចរិតនោះ ព្រះអម្ចាស់បានដកយកសិទ្ធិអំណាច និង កូនសោទាំងឡាយនៃបព្វជិតភាពចេញពីផែនដី ។ ទោះជាមានមនុស្សល្អ និងស្មោះត្រង់ជាច្រើនដែលបានថ្វាយបង្គំព្រះស្របតាមពន្លឺដែលពួកគេមាន និងបានទទួលចម្លើយចំពោះការអធិស្ឋានរបស់ពួកគេក្តី ក៏ពិភពលោកត្រូវបានទុកចោល ដោយគ្មានវិវរណៈពីព្រះតាមរយៈព្យាការីដែលនៅរស់ដែរ ។ គ្រានេះគឺត្រូវបានស្គាល់ថាជាការក្បត់សាសនាដ៏ធំ ។

៤.៧. អំឡុងពេលផ្សេងទៀតនៃការក្បត់សាសនា បានកើតឡើងពេញក្នុងប្រវត្តិសាស្ត្រនៃពិភពលោក ។

ប្រធានបទដែលទាក់ទង ៖ ពួកព្យាការី និងវិវរណៈ បព្វជិតភាព និងកូនសោបព្វជិតភាព ពិធីបរិសុទ្ធ និងសេចក្តីសញ្ញាទាំងឡាយ

## គ្រាកាន់កាប់ត្រួតត្រានៃដំណឹងល្អ

៤.៨. នៅពេលកូនចៅរបស់ព្រះបានធ្លាក់ទៅក្នុងស្ថានភាពនៃការក្បត់សាសនា នោះទ្រង់បានឈោងព្រះហស្តដោយក្តីស្រឡាញ់ទៅជួយពួកគេ តាមរយៈការហៅពួកព្យាការី និងការប្រទានពរជ័យនៃដំណឹងល្អជាថ្មីតាមរយៈពួកព្យាការីរបស់ទ្រង់ទៅដល់ប្រជាជន ។ អំឡុងពេលដែលព្រះអម្ចាស់បើកសម្តែងសេចក្តីពិតរបស់ទ្រង់ នោះសិទ្ធិអំណាចបព្វជិតភាព និងពិធី បរិសុទ្ធនានាត្រូវបានហៅថាគ្រាកាន់កាប់ត្រួតត្រាមួយ ។ វាគឺជាអំឡុងពេលមួយដែលយ៉ាងហោចណាស់ ព្រះអម្ចាស់មានអ្នកបម្រើដែលបានទទួលសិទ្ធិអំណាចម្នាក់នៅលើផែនដី ដែលកាន់បព្វជិតភាពបរិសុទ្ធ និង ជាអ្នកដែលមាននូវការអនុញ្ញាតពីព្រះដើម្បីចែកចាយដំណឹងល្អ និង ដើម្បីចាត់ចែងពិធីបរិសុទ្ធដែលមានក្នុងដំណឹងល្អនោះ ។

៤.៩. គ្រាកាន់កាប់ត្រួតត្រាត្រូវបានស្គាល់តាមរយៈ អ័ដាម អេណុក ណូអេ អ័ប្រាហាំ ម៉ូសេ ព្រះយេស៊ូវគ្រីស្ទ និងអ្នកដទៃទៀត ។ ការស្តារឡើងវិញនៃដំណឹងល្អនៅថ្ងៃចុងក្រោយ ដែលព្រះអម្ចាស់បានចាប់ផ្តើមតាមរយៈព្យាការីយ៉ូសែប ស្ម៊ីធ គឺជាចំណែកនៃលំនាំនៃគ្រាកាន់កាប់ត្រួតត្រានេះ ។

៤.១០. នៅគ្រប់គ្រាកាន់កាប់ត្រួតត្រា ព្រះអម្ចាស់ និងពួកព្យាការីរបស់ទ្រង់បានព្យាយាមស្ថាបនាស៊ីយ៉ូនឡើង ។ ស៊ីយ៉ូនសំដៅទៅលើរាស្ត្រនៃសេចក្តីសញ្ញារបស់ព្រះ ដែលមានភាពបរិសុទ្ធនៅក្នុងដួងចិត្ត មាន សាមគ្គីភាពនៅក្នុងសេចក្តីសុចរិត ហើយមើលថែគ្នាទៅវិញទៅមក ( សូមមើលម៉ូសេ ៧:១៨ ) ។ ស៊ីយ៉ូនក៏សំដៅទៅលើកន្លែងមួយដែលមានភាពបរិសុទ្ធនៅក្នុងចិត្តផងដែរ ។

៤.១១. សព្វថ្ងៃនេះ យើងកំពុងរស់នៅក្នុងគ្រាកាន់កាប់ត្រួតត្រាចុងក្រោយ—ជាគ្រាកាន់កាប់ត្រួតត្រានៃពេលពេញកំណត់ ។ វាគឺជាគ្រាកាន់កាប់ត្រួតត្រាតែមួយគត់ ដែលនឹងពុំបញ្ចប់ដោយការក្បត់សាសនាឡើយ ។ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ នឹងមានពេញនៅលើផែនដីទាំងមូល ហើយនឹងឈរនៅជារៀងរហូតដល់ទីបំផុត ( សូមមើលដានីយ៉ែល ២:៤៤ ) ។

ប្រធានបទដែលទាក់ទង ៖ ពួកព្យាការី និងវិវរណៈ បព្វជិតភាព និងកូនសោបព្វជិតភាព ពិធីបរិសុទ្ធ និងសេចក្តីសញ្ញាទាំងឡាយ

# ៥. ពួកព្យាការី និង វិវរណៈ



៥.១. ព្យាការីគឺជាមនុស្សម្នាក់ដែលត្រូវបានហៅដោយ ព្រះដើម្បីថ្លែងជំនួសទ្រង់ ( សូមមើលយេរេមា ១:៤-៥,អេម៉ុស ៣:៧,យ៉ូហាន ១៥:១៦,គ. និងស. ១:៣៧-៣៨ ) ។ ពួកព្យាការីទាំងឡាយថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ និង បង្រៀនដំណឹងល្អរបស់ទ្រង់ ។ ពួកលោកបង្ហាញឲ្យស្គាល់នូវព្រះហឫទ័យ និង ចរិតលក្ខណៈពិតរបស់ព្រះ ។ ពួកលោកថ្កោលទោសចំពោះអំពើបាប ព្រមានពីលទ្ធផលរបស់វា ហើយជួយយើងឲ្យចៀសវាងពីការបោកបញ្ឆោត ( សូមមើល អេសេគាល ៣:១៦-១៧,អេភេសូរ ៤:១១-១៤ ) ។ ជួនកាល ពួកលោកព្យាករអំពីព្រឹត្តិការណ៍នានានៃ ពេលអនាគត ។ ពួកព្យាការីអាចធ្វើនូវការទទួលខុសត្រូវទាំងនេះ ដោយសារពួកលោកទទួលបាននូវសិទ្ធិអំណាច និង វិវរណៈមកពីព្រះ ។

៥.២. វិវរណៈគឺជាទំនាក់ទំនងរវាងព្រះទៅកាន់កូនចៅរបស់ទ្រង់ ។ វិវរណៈភាគច្រើនកើតមានតាមរយៈចំណាប់ អារម្មណ៍ គំនិត និងអារម្មណ៍មកពីព្រះវិញ្ញាណបរិសុទ្ធ ។ វិវរណៈអាចកើតមានតាមរយៈការនិមិត្តការយល់សុបិន និង ការយាងមកជួបពីពួកទេវតាផងដែរ ។

៥.៣. អំឡុងការបម្រើនៃជីវិតរមែងស្លាប់របស់ទ្រង់ និងនៅក្នុងជំនាន់របស់យើងជាថ្មីម្ដងទៀត ព្រះអម្ចាស់បានរៀបចំសាសនាចក្ររបស់ទ្រង់នៅលើគ្រឹះនៃពួកព្យាការី និងពួកសាវក ( សូមមើលអេភេសូរ ២:១៩-២០ ) ។ ប្រធាននៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយគឺជាព្យាការីរបស់ព្រះសម្រាប់មនុស្សគ្រប់រូបនៅលើផែនដីនាពេលសព្វថ្ងៃនេះ ។ យើងគាំទ្រប្រធាននៃសាសនាចក្រជា ព្យាការី អ្នកមើលឆុត និង ជាអ្នកទទួលវិវរណៈ និងជាបុរសតែម្នាក់គត់នៅលើផែនដី ដែលទទួលវិវរណៈដើម្បីដឹកនាំសាសនាចក្រទាំងមូល ។ ប្រសិនបើយើងទទួល និងគោរពតាមការបង្រៀនរបស់ប្រធានសាសនាចក្រដោយស្មោះត្រង់ នោះព្រះនឹងប្រទានពរដល់យើងឲ្យយកឈ្នះលើការបោកបញ្ឆោត និងសេចក្ដីអាក្រក់ ( សូមមើលគ. និង ស. ២១:៤-៦ ) ។ យើងក៏គាំទ្រដល់ទីប្រឹក្សាទាំងឡាយនៅក្នុងគណៈប្រធានទីមួយ និង សមាជិកនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ជាព្យាការី អ្នកមើលឆុត និង ជាអ្នកទទួលវិវរណៈផងដែរ ។

៥.៤. ព្រះគម្ពីរនានា—ព្រះគម្ពីរបរិសុទ្ធ ព្រះគម្ពីរមរមន គោលលទ្ធិ និងសេចក្ដីសញ្ញា និង មុក្ដាដ៏មានតម្លៃមហិមា—មាននូវវិវរណៈទាំងឡាយ ដែលបានផ្ដល់តាមរយៈព្យាការីពីបុរាណ និង ព្យាការីថ្ងៃចុងក្រោយ ។ នៅពេលយើងសិក្សាប្រសាសន៍របស់ព្យាការី នោះយើងអាចរៀនពីសេចក្ដីពិត និងទទួលបាននូវការណែនាំ ។

៥.៥. ខណៈដែល ព្រះ ប្រទាន វិវរណៈតាមរយៈពួកព្យាការីដើម្បី ដឹកនាំកូនចៅរបស់ ទ្រង់ទាំងអស់ នោះបុគ្គលម្នាក់ៗអាចទទួលវិវរណៈដើម្បី ជួយ ពួកគេតាមតម្រូវការ ការទទួលខុសត្រូវ និងសំណួរជាក់លាក់ទាំងឡាយរបស់ពួកគេ ហើយជួយពង្រឹងដល់ទីបន្ទាល់របស់ពួកគេ ។ ទោះជាយ៉ាងណាក៏ដោយ ការបំផុសគំនិតផ្ទាល់ ខ្លួនដែលបានមកពីព្រះអម្ចាស់ នឹងមិនដែលផ្ទុយនឹងវិវរណៈដែលព្រះបានប្រទានតាមរយៈពួកព្យាការីរបស់ទ្រង់នោះឡើយ ។

សេចក្ដីយោងដែលទាក់ទង ៖ អ័ប្រាហាំ ៣:២២–២៣, ម៉ាថាយ ១៦:១៥–១៩, ធីម៉ូថេទី ២ ៣:១៥–១៧, នីហ្វៃទី ២ ៣២:៣, គ. និង ស. ៨:២–៣, គ. និង ស. ៧៦:២២–២៤

ប្រធានបទដែលទាក់ទង ៖ ការទទួលបានចំណេះដឹងខាងវិញ្ញាណ បព្វជិតភាព និង កូនសោទាំងឡាយនៃបព្វជិតភាព

# ៦. បព្វជិតភាព និង កូនសោទាំងឡាយនៃបព្វជិតភាព



៦.១. បព្វជិតភាពគឺជាអំណាច និង ជាសិទ្ធិអំណាចដ៏អស់កល្បរបស់ព្រះ ។ តាមរយៈបព្វជិតភាព ព្រះបានបង្កើត និងគ្រប់គ្រងស្ថានសួគ៌ ព្រមទាំងផែនដីផងដែរ ។ តាមរយៈអំណាចនេះ ទ្រង់ប្រោសលោះ និងលើកតម្កើងកូនចៅរបស់ទ្រង់ ។ បព្វជិតភាពត្រូវបានប្រគល់ដល់សមាជិកបុរស ដែលមានភាពសក្តិសមក្នុងសាសនាចក្រ ។ ពរជ័យនៃបព្វជិតភាពមានសម្រាប់កូនចៅទាំងអស់របស់ព្រះតាមរយៈពិធីបរិសុទ្ធ និងសេចក្តីសញ្ញាទាំងឡាយនៃដំណឹងល្អ ។

៦.២. កូនសោនៃបព្វជិតភាពគឺជាសិទ្ធិនៃគណៈប្រធាន ឬ ជាអំណាចដែលព្រះបានប្រទានដល់បុរសដើម្បីគ្រប់គ្រង ហើយដឹកនាំនគររបស់ព្រះនៅលើផែនដី ( សូមមើល ម៉ាថាយ ១៦:១៥–១៩ ) ។ កូនសោបព្វជិតភាពគឺចាំបាច់ដើម្បីដឹកនាំការផ្សាយដំណឹងល្អ និងការគ្រប់គ្រងនៃពិធីបរិសុទ្ធនៃសេចក្តីសង្រ្គោះ ។

៦.៣. ព្រះយេស៊ូវគ្រីស្ទកាន់កូនសោបព្វជិតភាពទាំងអស់សម្រាប់សាសនាចក្ររបស់ទ្រង់ ។ ទ្រង់បានប្រទានឲ្យពួកសាវករបស់ទ្រង់ម្នាក់ៗនូវរាល់កូនសោ ដែលមានសម្រាប់នគរព្រះនៅលើផែនដី ។ ប្រធាននៃសាសនាចក្រគឺជាមនុស្សតែម្នាក់គត់ ដែលមានសិទ្ធិអំណាចដើម្បីអនុវត្តគ្រប់កូនសោបព្វជិតភាពទាំងអស់ ។ ប្រធានព្រះវិហារបរិសុទ្ធ ប្រធានបេសកកម្ម ប្រធានស្តេក ប៊ីស្សព និងប្រធានកូរ៉ុមក៏មានកាន់កូនសោបព្វជិតភាពផងដែរ ដែលវាអនុញ្ញាតឲ្យពួកគាត់ធ្វើជាអធិបតី និងដឹកនាំកិច្ចការដែលពួកគាត់ត្រូវបានចាត់តាំងឲ្យធ្វើ ។

៦.៤. ចំពោះអស់អ្នកទាំងឡាយណាដែលបម្រើនៅក្នុងសាសនាចក្រ—ទាំងបុរស និងស្ត្រី—គឺត្រូវបានហៅក្រោមការដឹកនាំនៃបុគ្គលម្នាក់ ដែលកាន់កូនសោទាំងឡាយនៃបព្វជិតភាព( សូមមើល គ. និង ស. ៤២:១១ ) ។ អែលឌើរ ដាល្លិន  អេក អូក ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា « នរណាក៏ដោយដែលធ្វើកិច្ចការនៅក្នុងមុខតំណែង ឬការហៅបម្រើមួយដែលបានទទួលពីបុគ្គលម្នាក់ដែលកាន់កូនសោបព្វជិភាព អនុវត្តសិទ្ធិអំណាចបព្វជិតភាពពេលបំពេញកាតព្វកិច្ចចាត់តាំងរបស់គេ » ( « The Keys and Authority of the Priesthood »*Ensign*ឬ *Liahona*ខែ ឧសភា ឆ្នាំ ២០១៤ ទំព័រ  ៥១ ) ។ សិទ្ធិអំណាចបព្វជិតភាពអាចអនុវត្តបានតែនៅក្នុងសេចក្តីសុចរិតប៉ុណ្ណោះ( សូមមើល គ. និង ស. ១២១:៣៦, ៤១–៤២ ) ។

៦.៥. អ្នកទាំងឡាយដែលត្រូវបានតែងតាំងឲ្យមានបព្វជិតភាពមិលគីស្សាដែក គឺបានចូលក្នុងសម្បថ និងសេចក្តីសញ្ញានៃបព្វជិតភាព ។ ប្រសិនបើពួកគេតម្កើងការហៅ និងទទួលព្រះអម្ចាស់ និងពួកអ្នកបម្រើរបស់ទ្រង់ដោយស្មោះត្រង់ នោះពួកគេនឹងទទួលបានពរជ័យនៃការលើកតម្កើង ។ ស្រ្តីក៏ត្រូវបានសន្យាដូចគ្នានូវពរជ័យនៃការលើកតម្កើង នៅពេលពួកគេស្មោះត្រង់ចំពោះសេចក្តីសញ្ញាដែលពួកគេបានធ្វើជាមួយនឹងព្រះអម្ចាស់ ។

សេចក្តីយោងដែលទាក់ទង ៖ យ៉ូហាន ១៥:១៦,អេភេសូរ ២:១៩–២០

ប្រធានបទដែលទាក់ទង ៖ ការស្តារឡើងវិញ ពួកព្យាការី និង វិវរណៈ ពិធីបរិសុទ្ធ និងសេចក្តីសញ្ញាទាំងឡាយ

## បព្វជិតភាពអើរ៉ុន

៦.៦. ជាទូទៅបព្វជិតភាពអើរ៉ុនត្រូវបានហៅថាជាបព្វជិតភាពបម្រុង ។ បព្វជិតភាពអើរ៉ុន « កាន់ នូវ កូនសោ នៃ ការបម្រើនៃពួកទេវតា និង នៃ ដំណឹងល្អ នៃ ការប្រែចិត្ត និង បុណ្យជ្រមុជទឹក »( គ. និង ស. ១៣:១ ) ។ តាមរយៈការអនុវត្តបព្វជិតភាពនេះ ពិធីសាក្រាម៉ង់ត្រូវបានរៀបចំឡើង ប្រសិទ្ធពរ និងបម្រើ ។ មុខតំណែងនៃបព្វជិតភាពអើរ៉ុនរួមមាន ឌីកុន គ្រូ សង្ឃ និង ប៊ីស្សព ។

## បព្វជិតភាពមិលគីស្សាដែក

៦.៧. បព្វជិតភាពមិលគីស្សាដែកគឺជាបព្វជិតភាពខ្ពស់ជាង ឬធំជាង ហើយ « មានសិទ្ធិខាងគណៈប្រធាន ហើយមានអំណាច និងសិទ្ធិអំណាចលើអស់ទាំងតំណែងនៅក្នុងសាសនាចក្រ នៅគ្រប់សម័យនានាក្នុងពិភពលោក និងមានអំណាចដើម្បីចាត់ចែងការណ៍ទាំងឡាយខាងវិញ្ញាណ » ( គ. និង ស. ១០៧:៨ ) ។ គ្រប់ពរជ័យ ពិធីបរិសុទ្ធ សេចក្តីសញ្ញា និងការរៀបចំទាំងអស់របស់សាសនាចក្រ គឺត្រូវបានគ្រប់គ្រងនៅក្រោមសិទ្ធិអំណាចនៃប្រធានសាសនាចក្រ ដែលជាប្រធាននៃបព្វជិតភាពមិលគីស្សាដែក ។ បព្វជិតភាពត្រូវបានផ្តល់ឲ្យដល់អ័ដាម ហើយមាននៅលើផែនដី នៅពេលណាដែលព្រះអម្ចាស់បានបើកសម្តែងដំណឹងល្អរបស់ទ្រង់ ។ នៅក្នុងបព្វជិតភាពមិលគីស្សាដែកមាននូវមុខតំណែងដូចជា អែលឌើរ សង្ឃជាន់ខ្ពស់លោកអយ្យកោ ពួកចិតសិបនាក់ និងពួកសាវក ។

ខគម្ពីរយោងដែលទាក់ទង ៖ អេភេសូរ ៤:១១–១៤

# ៧. ពិធីបរិសុទ្ធ និង សេចក្ដីសញ្ញាទាំងឡាយ



## ពិធីបរិសុទ្ធទាំងឡាយ

៧.១. ពិធីបរិសុទ្ធគឺជាកិច្ចការដ៏ពិសិដ្ឋមួយដែលត្រូវបានធ្វើឡើងដោយសិទ្ធិអំណាចនៃបព្វជិតភាព ។ ពិធីបរិសុទ្ធនិមួយៗត្រូវបានបង្កើតឡើងដោយព្រះដើម្បីបង្រៀនពីសេចក្ដីពិតខាងវិញ្ញាណ ជាញឹកញាប់តាមរយៈនិមិត្តសញ្ញា ។

៧.២. ពិធីបរិសុទ្ធមួយចំនួនមានសារសំខាន់ចំពោះការលើកតម្កើង និង ត្រូវបានគេហៅថាជាពិធីបរិសុទ្ធសម្រាប់ការសង្គ្រោះ ។ មានតែតាមរយៈការទទួលពិធីបរិសុទ្ធនៃការសង្គ្រោះនិងការរក្សាសេចក្ដីសញ្ញាដែលជាប់ទាក់ទងប៉ុណ្ណោះទើបយើងអាចទទួលបានគ្រប់ទាំងពរជ័យដែលមានតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ បើគ្មានពិធីបរិសុទ្ធនៃការសង្គ្រោះទាំងនេះទេ នោះយើងមិនអាចប្រែក្លាយដូចជាព្រះវរបិតាសួគ៌របស់យើង ឬត្រឡប់ទៅរស់នៅក្នុងវត្តមានរបស់ទ្រង់ដ៏អស់កល្បជានិច្ចបានឡើយ ( សូមមើលគ. និង ស. ៨៤:២០-២២ ) ។ ពិធីបរិសុទ្ធនៃការសង្គ្រោះត្រូវបានធ្វើឡើងនៅក្រោមការដឹកនាំនៃអ្នកទាំងឡាយដែលកាន់កូនសោបព្វជិតភាព ។

៧.៣. ពិធីបរិសុទ្ធសម្រាប់ការសង្គ្រោះដំបូងគេនៃដំណឹងល្អគឺ ពិធីបុណ្យជ្រមុជទឹកដោយការជ្រមុជទៅក្នុងទឹក ដោយអ្នកមានសិទ្ធិអំណាច ។ បុណ្យជ្រមុជទឹកគឺចាំបាច់សម្រាប់បុគ្គលម្នាក់ៗ ដើម្បីក្លាយជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ និងដើម្បីចូលទៅក្នុងនគរសេឡេស្ទាល ( សូមមើល យ៉ូហាន ៣:៥ ) ។

៧.៤. បន្ទាប់ពីមនុស្សម្នាក់បានទទួលបុណ្យជ្រមុជទឹកហើយអ្នកកាន់បព្វជិតភាពមិលគីស្សាដែកម្នាក់ ឬច្រើននាក់បញ្ជាក់គាត់ ឬនាង ជាសមាជិកមួយរូបនៃសាសនាចក្រ ហើយផ្ដល់ដល់គាត់ ឬនាងនូវអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ( សូមមើលនីហ្វៃទី ៣ ២៧:២០ ) ។ អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធខុសពីឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ ។ ពីមុនពិធីបុណ្យជ្រមុជទឹក មនុស្សម្នាក់អាចមានអារម្មណ៍ពីឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ ហើយទទួលទីបន្ទាល់មួយនៃសេចក្ដីពិត ។ បន្ទាប់ពីទទួលបានអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ មនុស្សម្នាក់ដែលរក្សាសេចក្ដីសញ្ញារបស់គាត់ ឬនាង មានសិទ្ធិទទួលបានភាពជាដៃគូដ៏ខ្ជាប់ខ្ជួននៃព្រះវិញ្ញាណបរិសុទ្ធ ។

៧.៥. ពិធីបរិសុទ្ធនៃការសង្គ្រោះផ្សេងទៀត រួមមានការតែងតាំងដល់បព្វជិតភាពមិលគីស្សាដែក ( សម្រាប់បុរស ) អំណោយទានពិសិដ្ឋក្នុងព្រះវិហារបរិសុទ្ធ និងពិធីផ្សារភ្ជាប់អាពាហ៍ពិពាហ៍ ។ នៅក្នុងព្រះវិហារបរិសុទ្ធ ពិធីបរិសុទ្ធសម្រាប់ការសង្គ្រោះអាចនឹងត្រូវបានធ្វើឡើងជំនួសមរណជន ។ ពិធីបរិសុទ្ធជំនួសអាចមានប្រសិទ្ធភាពបាន លុះត្រាតែបុគ្គលដែលបានស្លាប់នោះទទួលយកពិធីទាំងនេះនៅក្នុងពិភពវិញ្ញាណហើយគោរពតាមសេចក្ដីសញ្ញាដែលមានពាក់ព័ន្ធតែប៉ុណ្ណោះ ។

៧.៦. ពិធីបរិសុទ្ធដទៃទៀតដូចជា ការទទួលទានសាក្រាម៉ង់ដើម្បីរំឭកចាំសេចក្ដីសញ្ញាបុណ្យជ្រមុជទឹករបស់យើង ការប្រសិទ្ធពរអ្នកឈឺ និង ការដាក់ឈ្មោះ និងការប្រសិទ្ធពរកុមារ ក៏ជាកិច្ចការសំខាន់ផងដែរសម្រាប់ការអភិវឌ្ឍខាងវិញ្ញាណរបស់យើង ។

សេចក្ដីយោងដែលទាក់ទង ៖ ម៉ាទ្បាគី ៤:៥–៦,ម៉ាថាយ ១៦:១៥–១៩,ពេត្រុសទី ១ ៤:៦,គ. និង ស. ១៣១:១–៤

ប្រធានបទដែលទាក់ទង ៖ ក្រុមព្រះ ៖ ព្រះវិញ្ញាណបរិសុទ្ធ ផែនការនៃសេចក្ដីសង្គ្រោះ ៖ ជីវិតបន្ទាប់ពីសេចក្ដីស្លាប់ ដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ បព្វជិតភាព និង កូនសោទាំងឡាយនៃបព្វជិតភាព

## សេចក្ដីសញ្ញាទាំងឡាយ

៧.៧. សេចក្ដីសញ្ញាគឺជាកិច្ចព្រមព្រៀងដ៏ពិសិដ្ឋមួយរវាងព្រះ និងមនុស្ស ។ ព្រះប្រទាននូវលក្ខខណ្ឌទាំងឡាយសម្រាប់សេចក្ដីសញ្ញា ហើយយើងយល់ព្រមធ្វើតាមនូវអ្វីដែលទ្រង់សុំឲ្យយើងធ្វើ បន្ទាប់មកព្រះសន្យាដល់យើងនូវពរជ័យជាក់លាក់មួយចំនួន នៅពេលយើងគោរពប្រតិបត្តិតាម ( សូមមើល និក្ខមនំ ១៩:៥–៦,គ. និង ស. ៨២:១០ ) ។ ប្រសិនបើយើងមិនគោរពតាមសេចក្ដីសញ្ញារបស់យើងទេ នោះយើងនឹងពុំទទួលបានពរជ័យដែលបានសន្យានោះឡើយ ។

៧.៨. រាល់ពិធីបរិសុទ្ធសម្រាប់ការសង្គ្រោះនៃបព្វជិតភាព មានអមជាមួយនូវសេចក្ដីសញ្ញាផ្សេងៗ ។ ឧទាហរណ៍ យើងចុះសេចក្ដីសញ្ញាជាមួយនឹងព្រះអម្ចាស់តាមរយៈបុណ្យជ្រមុជទឹក ( សូមមើល ម៉ូសាយ ១៨:៨–១០ ) ។ បុរសដែលទទួលបព្វជិតភាពមិលគីស្សាដែកនឹងបានចូលទៅក្នុងសម្បថ និង សេចក្ដីសញ្ញានៃបព្វជិតភាព ។ យើងរំឭកសេចក្ដីសញ្ញាដែលយើងបានធ្វើតាមរយៈការទទួលទានសាក្រាម៉ង់ ។

៧.៩. យើងធ្វើសេចក្ដីសញ្ញាបន្ថែម នៅពេលយើងទទួលពិធីបរិសុទ្ធនៃការសង្គ្រោះនៃអំណោយទានពិសិដ្ឋ និងការផ្សារភ្ជាប់អាពាហ៍ពិពាហ៍នៅក្នុងព្រះវិហារបរិសុទ្ធ ។ យើងរៀបចំចូលរួមនៅក្នុងពិធីបរិសុទ្ធនានា និងធ្វើសេចក្ដីសញ្ញានៅក្នុងព្រះវិហារបរិសុទ្ធ តាមរយៈការរស់នៅតាមបទដ្ឋាននៃភាពសក្ដិសមដែលព្រះអម្ចាស់បានដាក់ឲ្យ ( សូមមើលទំនុកតម្កើង ២៤:៣-៤ ) ។ វាជាការសំខាន់ ដែលយើងត្រូវមានភាពសក្ដិសមដើម្បីចូលក្នុងព្រះវិហារបរិសុទ្ធ ដោយសារព្រះវិហារបរិសុទ្ធគឺពិតជាដំណាក់របស់ព្រះអម្ចាស់ ។ វាគឺជាកន្លែងថ្វាយបង្គំដ៏បរិសុទ្ធបំផុតលើសពីកន្លែងណាៗនៅលើផែនដីនេះ ។

# ៨. អាពាហ៍ពិពាហ៍ និង គ្រួសារ



៨.១. អាពាហ៍ពិពាហ៍រវាងបុរស និងស្ត្រីត្រូវបានតែងតាំងឡើងដោយព្រះ ហើយ គ្រួសារគឺជាផ្នែកសំខាន់ចំពោះផែនការនៃសេចក្តីសង្គ្រោះ និង សុភមង្គលរបស់យើង ( សូមមើល លោកុប្បត្តិ ២:២៤, គ. និង ស. ៤៩:១៥–១៧ ) ។ មានតែតាមរយៈការចូល និងការរក្សាសេចក្តីសញ្ញានៃអាពាហ៍ពិពាហ៍ដ៏ស្មោះត្រង់ប៉ុណ្ណោះ ទើបបុរសម្នាក់ និងស្ត្រីម្នាក់ អាចបំពេញនូវសក្តានុពលដ៏ទេវភាពដ៏អស់កល្បជានិច្ចរបស់ពួកគេបាន ( សូមមើលកូរិនថូសទី ១ ១១:១១,គ. និង ស. ១៣១:១-៤ ) ។

៨.២. ព្រះបានបញ្ជាកូនចៅរបស់ទ្រង់ឲ្យបង្កើតកូនចៅជាច្រើនឡើង ហើយមានពាសពេញលើផែនដី ( សូមមើលលោកុប្បត្តិ ១:២៨ ) ។ អំណាចដ៏ពិសិដ្ឋនៃការបង្កបង្កើត គឺត្រូវបានប្រើតែរវាងបុរសម្នាក់ និងស្ត្រីម្នាក់ ដែលបានរៀបការស្របច្បាប់ក្នុងនាមជាស្វាមី និងភរិយាប៉ុណ្ណោះ ( សូមមើលលោកុប្បត្តិ ៣៩:៩,អាលម៉ា ៣៩:៩ ) ។ ស្វាមី និង ភរិយាមានការទទួលខុសត្រូវដ៏ឧឡារិកដើម្បីស្រឡាញ់ និងថែរក្សាគ្នាទៅវិញទៅមក ព្រមទាំងកូនចៅរបស់ខ្លួនផងដែរ ។ ឪពុកម្តាយត្រូវចិញ្ចឹមបីបាច់កូនចៅរបស់ពួកគេប្រកបដោយសេចក្តីស្រឡាញ់ និងសេចក្តីសុចរិត ហើយផ្គត់ផ្គង់ដល់សេចក្តីត្រូវការខាងសាច់ឈាម និងខាងវិញ្ញាណរបស់ពួកគេ ។

៨.៣. សុភមង្គលនៅក្នុងជីវិតគ្រួសារអាចសម្រេចបាន នៅពេលស្ថាបនាលើការបង្រៀនរបស់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ។ តាមការរៀបចំដ៏ទេវភាពនេះ ឪពុកគឺជាអ្នកដឹកនាំលើក្រុមគ្រួសាររបស់ពួកគេ ដោយសេចក្តីស្រឡាញ់ និងសេចក្តីសុចរិត និងបំពេញនូវសេចក្តីត្រូវការចាំបាច់នានាសម្រាប់ជីវិត ។ ម្តាយមានភារកិច្ចសំខាន់ ដើម្បីថែរក្សាបីបាច់កូនចៅរបស់ខ្លួន ។ នៅក្នុងការទទួលខុសត្រូវដ៏ពិសិដ្ឋទាំងនេះឪពុក និង ម្តាយមានកាតព្វកិច្ចដើម្បីជួយគ្នាទៅវិញទៅមកជាដៃគូស្មើគ្នា ។

៨.៤. ផែនការនៃសុភមង្គលដ៏ទេវភាពនេះផ្តល់លទ្ធភាពដល់ទំនាក់ទំនងក្រុមគ្រួសារឲ្យបន្តទៅហួសពីសេចក្តីស្លាប់ ។ ផែនដីត្រូវបានបង្កើតឡើង ហើយដំណឹងល្អត្រូវបានបើកសម្តែង ដូច្នេះក្រុមគ្រួសារត្រូវបានបង្កើតឡើង ត្រូវបានផ្សារភ្ជាប់ និងត្រូវបានតម្កើងឡើងដ៏អស់កល្បជានិច្ចដែរ ។ តាមរយៈការបម្រើក្នុងពង្សប្រវត្តិ និងព្រះវិហារបរិសុទ្ធ នោះយើងអាចធ្វើឲ្យពិធីបរិសុទ្ធ និងសេចក្តីសញ្ញាទាំងឡាយនៃដំណឹងល្អកើតមានសម្រាប់ជីដូនជីតារបស់យើង ( សូមមើលម៉ាឡាគី ៤:៥-៦ ) ។

( សម្របសម្រួលចេញមកពី« The Family: A Proclamation to the World »*Ensign*ឬ *Liahona*ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ១២៩ ។

សេចក្តីយោងដែលទាក់ទង ៖ ម៉ូសេ ១:៣៩, លោកុប្បត្តិ ១:២៦–២៧, និក្ខមនំ ២០:៣–១៧, ម៉ាថាយ ១៦:១៥–១៩, យ៉ូហាន ១៧:៣, កូរិនថូសទី ១ ៦:១៩–២០, នីហ្វៃទី ២ ២:២២–២៥, ម៉ូសាយ ២:៤១, អាលម៉ា ៤១:១០, គ. និង ស. ៨៤:២០–២២

ប្រធានបទដែលទាក់ទង ៖ ផែនការនៃសេចក្តីសង្គ្រោះ បទបញ្ញត្តិទាំងឡាយ

# ៩. បទបញ្ញត្តិទាំងឡាយ



៩.១. បទបញ្ញត្តិទាំងឡាយគឺជាច្បាប់ និងតម្រូវការដែលព្រះប្រទានឲ្យដើម្បីជួយយើងឲ្យរីកចម្រើន និងប្រែក្លាយដូចជាទ្រង់ ។ បទបញ្ញត្តិគឺជាការបើកសម្តែងសេចក្តីស្រឡាញ់របស់ព្រះមកកាន់យើង ។ យើងបង្ហាញសេចក្តីស្រឡាញ់របស់យើងចំពោះទ្រង់ ដោយការគោរពតាមបទបញ្ញត្តិទាំងឡាយរបស់ទ្រង់ ( សូមមើល យ៉ូហាន ១៤:១៥ ) ។ ការកាន់តាមបទបញ្ញត្តិទាំងឡាយ នឹងនាំមកនូវសុភមង្គល និងពរជ័យជាច្រើនមកពីព្រះអម្ចាស់ជានិច្ច ( សូមមើលម៉ូសាយ ២:៤១,អាលម៉ា ៤១:១០ ) ។ ព្រះនឹងមិនប្រទានបទបញ្ញត្តិមួយដល់យើងដោយពុំបានរៀបចំផ្លូវសម្រាប់ឲ្យយើងគោរពតាមនោះទេ ( សូមមើលនីហ្វៃទី ១ ៣:៧ ) ។

៩.២. បទបញ្ញត្តិគ្រឹះពីរធំបំផុតគឺ « ស្រឡាញ់ព្រះអម្ចាស់ជាព្រះនៃឯងឲ្យអស់ពីចិត្ត អស់អំពីព្រលឹង ហើយអស់អំពីគំនិតឯង ។. . . ហើយ. . . ស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង » ( សូមមើលម៉ាថាយ ២២:៣៦–៣៩ ) ។ យើងអាចស្រឡាញ់ និងបម្រើព្រះដោយការជ្រើសរើសដើម្បីស្រឡាញ់ និងបម្រើដល់អ្នកដទៃ ( សូមមើលម៉ូសាយ ២:១៧មរ៉ូណៃ ៧:៤៥, ៤៧-៤៨ ) ។

៩.៣. បទបញ្ញត្តិមួយនៃបទបញ្ញត្តិពីដើមដំបូងបំផុតដែលបានប្រទានដល់មនុស្សគឺរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ ។ ព្រះបញ្ជាឲ្យកូនចៅរបស់ទ្រង់គោរពទ្រង់តាមរយៈការធ្វើតាមព្រះទ័យរបស់ទ្រង់ ជាជាងធ្វើតាមចិត្តរបស់យើងនៅថ្ងៃឈប់សម្រាក ហើយទ្រង់សន្យានូវពរជ័យដ៏មហិមាចំពោះអ្នកទាំងឡាយណាដែលរក្សាថ្ងៃរបស់ទ្រង់បានបរិសុទ្ធ ( សូមមើល អេសាយ ៥៨:១៣-១៤ ) ។

៩.៤. ក្រឹត្យវិន័យទាំងដប់ប្រការគឺជាផ្នែកមួយដ៏សំខាន់នៃដំណឹងល្អ ហើយជាគោលការណ៍ដ៏នៅអស់កល្បដែលចាំបាច់សម្រាប់ភាពតម្កើងឡើងរបស់យើង ( សូមមើល និក្ខមនំ ២០:៣–១៧ ) ។ ព្រះអម្ចាស់បានបង្ហាញក្រឹត្យវិន័យទាំងនោះដល់ម៉ូសេ កាលពីសម័យបុរាណ ហើយទ្រង់បានលើកវាឡើងម្តងទៀតនៅក្នុងវិវរណៈនាថ្ងៃចុងក្រោយ ។

៩.៥. បញ្ញត្តិទាំងឡាយរបស់ព្រះរួមមាន ការអធិស្ឋានប្រចាំថ្ងៃ ការសិក្សាព្រះបន្ទូលរបស់ព្រះ ការប្រែចិត្ត ការគោរពតាមច្បាប់ព្រហ្មចារីភាព និងការថ្វាយដង្វាយមួយភាគក្នុងដប់ពេញលេញ ( សូមមើលម៉ាឡាគី ៣:៨-១០ ) ការតមអាហារ ( សូមមើលអេសាយ ៥៨:៦-៧ ) ការអភ័យទោសដល់អ្នកដទៃ ( សូមមើលគ. និង ស. ៦៤:៩-១១ ) ការគោរពតាមពាក្យសម្តីនៃប្រាជ្ញាវាងវៃ ( សូមមើលគ. និង ស. ៨៩:១៨-២១ ) និងការបង្រៀនដំណឹងល្អដល់អ្នកដទៃ ( សូមមើលម៉ាថាយ ៥:១៤-១៦,គ. និង ស. ១៨:១៥-១៦ ) ។

សេចក្តីយោងដែលទាក់ទង ៖ លោកុប្បត្តិ ៣៩:៩, ធីម៉ូថេទី ២ ៣:១៥–១៧, យ៉ាកុប ១:៥–៦, នីហ្វៃទី ២ ៣២:៣, នីហ្វៃទី ២ ៣២:៨–៩, ម៉ូសាយ ១៨:៨–១០, អាលម៉ា ៣៩:៩, នីហ្វៃទី ៣ ១៨:១៥, ២០–២១, គ. និងស. ៥៨:៤២–៤៣, គ. និងស. ៨២:១០

ប្រធានបទដែលទាក់ទង ៖ ការទទួលបានចំណេះដឹងខាងវិញ្ញាណ ដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ៖ ការប្រែចិត្ត ពិធីបរិសុទ្ធ និងសេចក្តីសញ្ញាទាំងឡាយ

# វគ្គចំណេះចំណាន ខាងគោលលទ្ធិ

# វគ្គចំណេះចំណានខាងគោលលទ្ធិតាមប្រធានបទ និង វគ្គសិក្សា

**ខាងក្រោមនេះគឺ ជាបញ្ជីនៃវគ្គចំណេះចំណានខាង គោលលទ្ធិទាំង ១០០ ដែលបានរៀបចំឡើងតាមប្រធានបទ និងវគ្គសិក្សា ៖**

| ប្រធានបទ | ព្រះគម្ពីរសញ្ញាចាស់ | ព្រះគម្ពីរសញ្ញាថ្មី | ព្រះគម្ពីរមរមន | គោលលទ្ធិ និងសេចក្ដីសញ្ញា និង ប្រវត្តិសាសនាចក្រ |
|---|---|---|---|---|
| ការទទួលបានចំណេះដឹងខាងវិញ្ញាណ | សុភាសិត៣:៥–៦<br>អេសាយ ៥:២០ | យ៉ូហាន ៧:១៧<br>កូរិនថូសទី ១ ២:៥, ៩–១១<br>ធីម៉ូថេទី ២ ៣:១៥–១៧<br>យ៉ាកុប ១:៥–៦ | នីហ្វៃទី ២ ២៨:៣០<br>នីហ្វៃទី ២ ៣២:៣<br>នីហ្វៃទី ២ ៣២:៨-៩<br>ម៉ូសាយ ៤:៩<br>អេធើរ ១២:៦<br>មរ៉ូណៃ ១០:៤–៥ | គ. និង ស. ៦:៣៦<br>គ. និង ស. ៨:២–៣<br>គ. និង ស. ៨៨:១១៨ |
| ១. ក្រុមព្រះ | | ហេព្រើរ ១២:៩ | នីហ្វៃទី ២ ២៦:៣៣<br>នីហ្វៃទី ៣ ១១:១០–១១<br>នីហ្វៃទី ៣ ១២:៤៨<br>នីហ្វៃទី ៣ ១៨:១៥, ២០–២១ | គ. និង ស. ២៩:១០–១១<br>គ. និង ស. ១៣០:២២–២៣ |
| ២. ផែនការនៃសេចក្ដីសង្គ្រោះ | ម៉ូសេ ១:៣៩<br>អ័ប្រាហាំ ៣:២២–២៣<br>លោកុប្បត្តិ ១:២៦–២៧<br>យ៉ូស្វេ ២៤:១៥ | យ៉ូហាន ១៧:៣<br>កូរិនថូសទី ១ ៦:១៩–២០<br>កូរិនថូសទី ១ ១៥:២០-២២<br>កូរិនថូសទី ១ ១៥:៤០-៤២<br>ពេត្រុសទី ១ ៤:៦<br>វិវរណៈ ២០:១២ | នីហ្វៃទី ២ ២:២២–២៥<br>នីហ្វៃទី ២ ២:២៧ | គ. និង ស. ៧៦:២២–២៤ |
| ៣. ដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ | អេសាយ ១:១៨<br>អេសាយ ៥៣:៣-៥ | ម៉ាថាយ ១១:២៨–៣០<br>លូកា ២៤:៣៦–៣៩<br>យ៉ាកុប ២:១៧–១៨ | ម៉ូសាយ ៣:១៩<br>អាលម៉ា ៧:១១–១៣<br>អាលម៉ា ៣៤:៩-១០<br>ហេលេមិន ៥:១២<br>អេធើរ ១២:២៧ | គ. និង ស. ១៨:១០–១១<br>គ. និង ស. ១៩:១៦–១៩<br>គ. និង ស. ៥៨:៤២–៤៣ |
| ៤. ការស្ដារឡើងវិញ | ម៉ូសេ ៧:១៨<br>អេសាយ ២៩:១៣–១៤<br>អេសេគាល ៣៧:១៥–១៧<br>ដានីយ៉ែល ២:៤៤ | កិច្ចការ ៣:១៩–២១<br>ថែស្សាឡូនីច ទី២ ២:១–៣ | | យ៉ូសែបស្ម៊ីធ—ប្រវត្តិ ១:១៥–២០<br>គ. និង ស. ១:៣០<br>គ. និង ស. ១៣៥:៣ |
| ៥. ពួកព្យាការី និង វិវរណៈ | យេរេមា ១:៤–៥<br>អេសេគាល ៣:១៦-១៧<br>អេម៉ុស ៣:៧ | យ៉ូហាន ១៥:១៦<br>អេភេសូរ ២:១៩-២០<br>អេភេសូរ ៤:១១–១៤ | | គ. និង ស. ១:៣៧–៣៨<br>គ. និង ស. ២១:៤–៦ |
| ៦. បព្វជិតភាព និង កូនសោទាំងឡាយនៃបព្វជិតភាព | | ម៉ាថាយ ១៦:១៥–១៩ | | គ. និង ស. ១៣:១<br>គ. និង ស. ៤២:១១<br>គ. និង ស. ១០៧:៨<br>គ. និង ស. ១២១:៣៦, ៤១–៤២ |
| ៧. ពិធីបរិសុទ្ធ និង សេចក្ដីសញ្ញាទាំងឡាយ | និក្ខមនំ ១៩:៥–៦<br>ទំនុកតម្កើង ២៤:៣–៤ | យ៉ូហាន ៣:៥ | ម៉ូសាយ ១៨:៨-១០<br>នីហ្វៃទី ៣ ២៧:២០ | គ. និង ស. ៨២:១០<br>គ. និង ស. ៨៤:២០-២២ |
| ៨. អាពាហ៍ពិពាហ៍ និង គ្រួសារ | លោកុប្បត្តិ ១:២៨<br>លោកុប្បត្តិ ២:២៤<br>លោកុប្បត្តិ ៣៩:៩<br>ម៉ាឡាគី ៤:៥–៦ | កូរិនថូសទី ១ ១១:១១ | អាលម៉ា ៣៩:៩ | គ. និង ស. ៤៩:១៥-១៧<br>គ. និង ស. ១៣១:១–៤ |
| ៩ បទបញ្ញត្តិទាំងឡាយ | និក្ខមនំ ២០:៣-១៧<br>អេសាយ ៥៨:៦-៧<br>អេសាយ ៥៨:១៣–១៤<br>ម៉ាឡាគី ៣:៨–១០ | ម៉ាថាយ ៥:១៤–១៦<br>ម៉ាថាយ ២២:៣៦–៣៩<br>យ៉ូហាន ១៤:១៥ | នីហ្វៃទី ១ ៣:៧<br>ម៉ូសាយ ២:១៧<br>ម៉ូសាយ ២:៤១<br>អាលម៉ា ៤១:១០<br>មរ៉ូណៃ ៧:៤៥, ៤៧–៤៨ | គ. និង ស. ១៨:១៥–១៦<br>គ. និង ស. ៦៤:៩–១១<br>គ. និង ស. ៨៩:១៨–២១ |

# វគ្គចំណេះចំណានខាងគោលលទ្ធិ និងឃ្លាសំខាន់ៗ

ខាងក្រោមនេះ គឺជាបញ្ជីនៃវគ្គចំណេះចំណានខាងគោលលទ្ធិចំនួន ១០០ រួមជាមួយនឹងសេចក្តីសង្ខេបខ្លីៗសម្រាប់វគ្គនីមួយៗ ។

## ការទទួលបានចំណេះដឹងខាងវិញ្ញាណ

សុភាសិត ៣:៥–៦ ។ ចូរទីពឹងដល់ព្រះយេហូវ៉ាឲ្យអស់អំពីចិត្ត នោះទ្រង់នឹងតម្រង់អស់ទាំងផ្លូវប្រែករបស់ឯង ។

អេសាយ ៥:២០ ។ វេទនាដល់ពួកអ្នកដែលរាប់សេចក្តីអាក្រក់ថាជាល្អ ហើយសេចក្តីល្អថាជាអាក្រក់វិញ ។

យ៉ូហាន ៧:១៧ ។ ធ្វើតាមព្រះហឫទ័យទ្រង់ ដើម្បីដឹងពីគោលលទ្ធិទ្រង់ ។

កូរិនថូសទី ១ ២:៥, ៩–១១ ។ យើងអាចដឹងអំពីសេចក្តីទាំងឡាយនៃព្រះបានតាមរយៈព្រះវិញ្ញាណ ។

ធីម៉ូថេទី ២ ៣:១៥–១៧ ។ ព្រះគម្ពីរអាចធ្វើឲ្យយើងមានប្រាជ្ញាដល់ទីសង្គ្រោះ ។

យ៉ាកុប ១:៥–៦ ។ បើអ្នកខ្វះប្រាជ្ញា ចូរសូមដល់ព្រះ ។

នីហ្វៃទី ២ ២៨:៣០ ។ ព្រះប្រទានចំណេះដឹងមួយបន្ទាត់ម្តងៗ ។

នីហ្វៃទី ២ ៣២:៣ ។ ប្រសិនបើយើងទទួលទានព្រះបន្ទូលទាំងឡាយនៃព្រះគ្រីស្ទ នោះយើងអាចដឹងនូវគ្រប់អ្វីទាំងអស់ដែលយើងត្រូវធ្វើ ។

នីហ្វៃទី ២ ៣២:៨–៩ ។ ប្រសិនបើយើងអធិស្ឋានជានិច្ច នោះព្រះនឹងញែកកិច្ចការរបស់យើង សម្រាប់ជាសុខុមាលភាពដល់ព្រលឹងយើង ។

ម៉ូសាយ ៤:៩ ។ សូមជឿដល់ព្រះចុះ ហើយសូមជឿចុះថា ទ្រង់មានគ្រប់ប្រាជ្ញា ។

អេធើរ ១២:៦ ។ សាក្សីកើតមាន បន្ទាប់ពីការសាកល្បងនៃសេចក្តីជំនឿ ។

មរ៉ូណៃ ១០:៤–៥ ។ ព្រះវិញ្ញាណបរិសុទ្ធបើកសម្តែងសេចក្តីពិត ដល់អស់អ្នកណាដែលទូលសួរដល់ព្រះដោយស្មោះអស់ពីចិត្ត ។

គ. និង ស. ៦:៣៦ ។ សូមគិតដល់ព្រះគ្រីស្ទគ្រប់គំនិតទាំងអស់ ។

គ. និង ស. ៨:២–៣ ។ ព្រះវិញ្ញាណបរិសុទ្ធមានបន្ទូលមកក្នុងគំនិត និងដួងចិត្តរបស់យើង ។

គ. និង ស. ៨៨:១១៨ ។ ចូរស្វែងរកការរៀនសូត្រដោយការសិក្សា និងដោយសេចក្តីជំនឿ ។

## ប្រធានបទនៃគោលលទ្ធិ

១. ក្រុមព្រះ

ហេព្រើរ ១២:៩ ។ ព្រះគឺជាព្រះវរបិតាខាងវិញ្ញាណរបស់យើង ។

នីហ្វៃទី ២ ២៦:៣៣ ។ មនុស្សទាំងអស់គ្នាគឺដូចគ្នានៅចំពោះព្រះ ។

នីហ្វៃទី ៣ ១១:១០–១១ ។ ព្រះយេស៊ូវគ្រីស្ទ បានស៊ូទ្រាំតាមព្រះហឫទ័យនៃព្រះវរបិតាចំពោះគ្រប់ការណ៍ទាំងអស់ ។

នីហ្វៃទី ៣ ១២:៤៨ ។ ព្រះយេស៊ូវគ្រីស្ទអញ្ជើញយើងឲ្យប្រែជាគ្រប់លក្ខណ៍ ។

នីហ្វៃទី ៣ ១៨:១៥, ២០–២១ ។ ចូរចាំយាម ហើយអធិស្ឋានជានិច្ចនៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ។

គ. និង ស. ២៩:១០–១១ ។ ព្រះគ្រីស្ទនឹងយាងមកម្តងទៀតដោយព្រះចេស្តា និង សិរីល្អ ។

គ. និង ស. ១៣០:២២–២៣ ។ ព្រះវរបិតា និងព្រះរាជបុត្រាមានព្រះកាយជាសាច់ និងឆ្អឹង ។

២. ផែនការនៃសេចក្តីសង្គ្រោះ

ម៉ូសេ ១:៣៩ ។ កិច្ចការ និងសិរីល្អរបស់ព្រះ គឺដើម្បីនាំឲ្យមានអមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស ។

អ័ប្រាហាំ៣:២២–២៣ ។ អ័ប្រាហាំត្រូវបានជ្រើសរើសពីមុនលោកបានចាប់កំណើតមកកម្លោះ ។

លោកុប្បត្តិ ១:២៦–២៧ ។ ព្រះបានបង្កើតមនុស្សតាមរូបអង្គទ្រង់ផ្ទាល់ ។

យ៉ូស្វេ ២៤:១៥ ។ ចូររើសយកព្រះណា ដែលឯងចង់គោរពប្រតិបត្តិតាមនៅថ្ងៃនេះចុះ ។

យ៉ូហាន ១៧:៣ ។ ជីវិតដ៏អស់កល្បជានិច្ច គឺជាការស្គាល់ព្រះ និងព្រះយេស៊ូវគ្រីស្ទ ។

កូរិនថូសទី ១ ៦:១៩–២០ ។ រូបកាយរបស់អ្នកជាព្រះវិហារបរិសុទ្ធ ។

កូរិនថូសទី ១ ១៥:២០–២២ ។ នៅក្នុងព្រះគ្រីស្ទគ្រប់គ្នានឹងត្រូវបានរស់ឡើងវិញ ។

កូរិនថូសទី ១ ១៥:៤០–៤២ ។ មានសិរីរុងរឿងបីកម្រិតនៅក្នុងការរស់ឡើងវិញ ។

ពេត្រុសទី ១ ៤:៦ ។ ដំណឹងល្អត្រូវបានផ្សាយដល់មរណជន ។

វិវរណៈ ២០:១២ ។ មនុស្សម្នាក់ៗនឹងឈរនៅចំពោះព្រះភក្ត្រព្រះដើម្បីទទួលការជំនុំជម្រះ ។

នីហ្វៃទី ២ ២:២២–២៥ ។ លោកអ័ដាមបានធ្លាក់ខ្លួនដើម្បីឲ្យមានមនុស្សលោក ។

នីហ្វៃទី ២ ២:២៧ ។ យើងមានសេរីភាពដើម្បីជ្រើសរើស ។

គ. និង ស. ៧៦:២២–២៤ ។ ព្រះយេស៊ូវគ្រីស្ទមានព្រះជន្មរស់ ហើយទ្រង់គឺជាអង្គបង្កបង្កើតពិភពលោកទាំងឡាយ ។

៣. ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ

អេសាយ ១:១៨ ។ ប្រសិនបើយើងប្រែចិត្ត នោះអំពើបាបរបស់យើងនឹងបានសដូចហិមៈ ។

អេសាយ ៥៣:៣-៥ ។ ព្រះយេស៊ូវគ្រីស្ទទទួលយកសេចក្តីឈឺចាប់របស់យើងហើយរងទុក្ខព្រោះអំពើបាបយើង ។

ម៉ាថាយ១១:២៨-៣០ ។ ប្រសិនបើយើងមករកព្រះយេស៊ូវគ្រីស្ទ នោះទ្រង់នឹងសម្រាលបន្ទុករបស់យើង ហើយឲ្យយើងបានសម្រាក ។

លូកា ២៤:៣៦-៣៩ ។ ព្រះយេស៊ូវគ្រីស្ទបានមានព្រះជន្មរស់ឡើងវិញ ដោយមានព្រះកាយជាសាច់ និងឆ្អឹង ។

យ៉ាកុប ២:១៧-១៨ ។ សេចក្ដីជំនឿដែលគ្មានការប្រព្រឹត្តតាម នោះឈ្មោះថាស្លាប់ ។

ម៉ូសាយ ៣:១៩ ។ សម្រាតភាពខាងសាច់ឈាមចេញ ហើយក្លាយទៅជាអ្នកបរិសុទ្ធវិញ តាមរយៈដង្វាយធួន ។

អាលម៉ា ៧:១១-១៣ ។ ព្រះយេស៊ូវគ្រីស្ទបានមានបទពិសោធន៍នៃការឈឺចាប់របស់យើង ហើយបានយកឈ្នះលើអំពើបាប និងសេចក្ដីស្លាប់ ។

អាលម៉ា ៣៤:៩-១០ ។ ត្រូវតែមានដង្វាយធួនមួយត្រូវបានធ្វើឡើង ។

ហេលេមិន ៥:១២ ។ ត្រូវសង់គ្រឹះរបស់អ្នកនៅលើព្រះគ្រីស្ទ ។

អេធើរ ១២:២៧ ។ ព្រះអង្គសង្គ្រោះអាចធ្វើឲ្យភាពទន់ខ្សោយប្រែជាខ្លាំងបាន ។

គ. និង ស. ១៨:១០-១១ ។ តម្លៃនៃព្រលឹងទាំងឡាយ គឺមហិមាណាស់ ។

គ. និង ស. ១៩:១៦-១៩ ។ ព្រះអង្គសង្គ្រោះបានរងទុក្ខជំនួសអំពើបាបរបស់យើង ដូច្នេះយើងអាចប្រែចិត្តបាន ។

គ. និង ស. ៥៨:៤២-៤៣ ។ ដើម្បីប្រែចិត្តយើងត្រូវតែសារភាព ហើយលះបង់ចោលអំពើបាប ។

## ៤. ការស្ដារឡើងវិញ

ម៉ូសេ ៧:១៨ ។ ស៊ីយ៉ូន—មានចិត្ត និង គំនិតតែមួយនៅក្នុងសេចក្ដីសុចរិត ។

អេសាយ ២៩:១៣-១៤ ។ ការស្ដារឡើងវិញគឺជាកិច្ចការអស្ចារ្យ ហើយចំឡែក ។

អេសេគាល ៣៧:១៥-១៧ ។ ព្រះគម្ពីរប៊ីប និងព្រះគម្ពីរមរមនត្រូវបានដាក់បញ្ចូលគ្នា ។

ដានីយ៉ែល ២:៤៤ ។ នគររបស់ព្រះនឹងស្ថិតស្ថេរនៅអស់កល្បជានិច្ច ។

កិច្ចការ ៣:១៩-២១ ។ ពេត្រុសបានព្យាករអំពីការស្ដារឡើងវិញ ។

ថែស្សាឡូនីចទី ២ ២:១-៣ ។ សេចក្ដីក្បត់សាសនាត្រូវបានព្យាករប្រាប់ ។

យ៉ូសែបស្ម៊ីធ—ប្រវត្តិ ១:១៥-២០ ។ នៅក្នុងការនិមិត្តដំបូង ព្រះបានហៅយ៉ូសែប ស្ម៊ីធ ឲ្យធ្វើជាព្យាការី ។

គ. និង ស. ១:៣០ ។ សាសនាចក្រតែមួយដែលពិត ហើយសកម្ម

គ. និង ស. ១៣៥:៣ ។ យ៉ូសែប ស្ម៊ីធ បានធ្វើកិច្ចការសម្រាប់សេចក្ដីសង្គ្រោះរបស់យើង ។

## ៥. ព្យាការី និង វិវរណៈ

យេរេមា ១:៤-៥ ។ យេរេមាត្រូវបានតែងតាំងពីមុនផែនដីមកម្ល៉េះ  ដើម្បីធ្វើជាព្យាការី ។

អេសេគាល ៣:១៦-១៧ ។ អ្នកយាមរបស់ព្រះអម្ចាស់ផ្ដល់សញ្ញាព្រមានមកពីទ្រង់ ។

អេម៉ុស ៣:៧ ។ ព្រះបើកសម្ដែងគំនិតលាក់កំបាំងរបស់ទ្រង់ដល់ពួកព្យាការីទ្រង់ ។

យ៉ូហាន ១៥:១៦ ។ ព្រះអម្ចាស់ជ្រើសរើស ហើយតែងតាំងពួកសាវក និងព្យាការី ។

អេភេសូរ ២:១៩-២០ ។ សាសនាចក្ររបស់ព្រះអម្ចាស់ត្រូវបានស្ថាបនាឡើងដោយមានពួកព្យាការី និងពួកសាវក ។

អេភេសូរ ៤:១១-១៤ ។ ពួកសាវក និង ព្យាការីជួយពួកបរិសុទ្ធឲ្យបានគ្រប់លក្ខណ៍ ។

គ. និង ស. ១:៣៧-៣៨ ។ សំឡេងរបស់ព្រះអម្ចាស់ និង សំឡេងរបស់អ្នកបម្រើទ្រង់គឺដូចតែគ្នា ។

គ. និង ស. ២១:៤-៦ ។ នៅពេលយើងទទួលប្រសាសន៍របស់ព្យាការីដោយក្ដីអត់ធ្មត់ និង ជំនឿ នោះព្រះនឹងកម្ចាត់អំណាចនៃសេចក្ដីងងឹតចេញ ។

## ៦. បព្វជិតភាព និង កូនសោទាំងឡាយនៃបព្វជិតភាព

ម៉ាថាយ ១៦:១៥-១៩ ។ ព្រះយេស៊ូវគ្រីស្ទសន្យាថានឹង ស្ថាបនាសាសនាចក្ររបស់ទ្រង់ ហើយប្រគល់កូនសោនៃនគរស្ថានសួគ៌ ។

គ. និង ស. ១៣:១ ។ កូនសោនៃបព្វជិតភាពអើរ៉ុន

គ. និង ស. ៤២:១១ ។ អ្នកតំណាងព្រះអម្ចាស់ត្រូវតែបានហៅដោយបុគ្គលម្នាក់ដែលមានសិទ្ធិអំណាច ។

គ. និង ស. ១០៧:៨ ។ សិទ្ធិអំណាចនៃបព្វជិតភាពមិលគីស្សាដែក

គ. និង ស. ១២១:៣៦, ៤១-៤២ ។ អំណាចបព្វជិតភាពអាស្រ័យលើភាពសុចរិតរបស់បុគ្គលនោះ ។

## ៧. ពិធីបរិសុទ្ធ និង សេចក្ដីសញ្ញាទាំងឡាយ

និក្ខមនំ ១៩:៥-៦ ។ ចូររក្សាសេចក្ដីសញ្ញារបស់យើង ហើយអ្នករាល់គ្នានឹងក្លាយជាប្រជាជាតិមួយដ៏បរិសុទ្ធ ។

ទំនុកតម្កើង ២៤:៣-៤ ។ ដើម្បីឈរយ៉ាងសក្ដិសមនៅក្នុងវត្តមានរបស់ព្រះអម្ចាស់បាន នោះយើងត្រូវតែមានដៃស្អាត និងចិត្តបរិសុទ្ធ ។

យ៉ូហាន ៣:៥ ។ យើងត្រូវតែបានកើតអំពីទឹក ហើយអំពីព្រះវិញ្ញាណ ដើម្បីចូលទៅក្នុងនគរព្រះបាន ។

ម៉ូសាយ ១៨:៨-១០ ។ តាមរយៈបុណ្យជ្រមុជទឹក យើងចុះសេចក្ដីសញ្ញាជាមួយព្រះ ។

នីហ្វៃទី ៣ ២៧:២០ ។ ចូរទទួលបុណ្យជ្រមុជទឹក ហើយញែកចេញបរិសុទ្ធដោយការទទួលនូវព្រះវិញ្ញាណបរិសុទ្ធ ។

គ. និង ស. ៨២:១០ ។ ព្រះអម្ចាស់ជាប់សន្យា កាលណាយើងរាល់គ្នាប្រព្រឹត្តតាមអ្វីដែលទ្រង់មានព្រះបន្ទូល ។

គ. និង ស. ៨៤:២០-២២ ។ អំណាចនៃព្រះត្រូវបានសម្ដែងឲ្យឃើញនៅក្នុងពិធីបរិសុទ្ធទាំងឡាយនៃបព្វជិតភាព ។

## ៨. អាពាហ៍ពិពាហ៍ និង គ្រួសារ

លោកុប្បត្តិ ១:២៨ ។ ចូរបង្កើតកូនឲ្យចម្រើនជាច្រើនឡើង ឲ្យមានពេញពាសលើផែនដីចុះ ។

លោកុប្បត្តិ ២:២៤ ។ ស្វាមី និង ភរិយាគឺជាមនុស្សតែមួយ ។

លោកុប្បត្តិ ៣៩:៩ ។ យ៉ូសែបបានទប់ទល់នឹងការល្បួង ។

ម៉ាឡាគី ៤:៥–៦ ។ អេលីយ៉ានឹងបង្វែរចិត្តរបស់ឪពុក និង កូន ។

កូរិនថូសទី ១ ១១:១១ ។ មានតែបុរស និង ស្ត្រីរួមគ្នាតែប៉ុណ្ណោះ ទើបអាច
បំពេញផែនការរបស់ព្រះអម្ចាស់បាន ។

អាលម៉ា៣៩:៩ ។ កុំទៅតាមសេចក្ដីសំរើបនៃភ្នែករបស់ខ្លួនឡើយ ។

គ. និង ស. ៤៩:១៥–១៧ ។ អាពាហ៍ពិពាហ៍រវាងបុរស និង ស្ត្រីត្រូវបាន
តែងតាំងឡើងដោយព្រះ ។

គ. និង ស. ១៣១:១–៤ ។ សេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ចនៃ
អាពាហ៍ពិពាហ៍

## ៩. បទបញ្ញត្តិទាំងឡាយ

និក្ខមនំ ២០:៣-១៧ ។ ព្រះបានបើកសម្ដែងអំពីក្រឹត្យវិន័យដប់ប្រការ ។

អេសាយ ៥៨:៦–៧ ។ ការតមអាហារជួយយើងឲ្យដោះច្រវាក់នៃអំពើទុច្ចរិត
សម្រាលបន្ទុកដ៏ធ្ងន់ និង ផ្គត់ផ្គង់ដល់ជនក្រីក្រ ។

អេសាយ ៥៨:១៣–១៤ ។ ថ្ងៃឈប់សម្រាកគឺជាថ្ងៃដ៏បរិសុទ្ធរបស់ព្រះអម្ចាស់ ។

ម៉ាឡាគី ៣:៨–១០ ។ ការថ្វាយដង្វាយមួយភាគក្នុងដប់នាំមកនូវពរជ័យ ។

ម៉ាថាយ ៥:១៤–១៦ ។ ចូរឲ្យពន្លឺរបស់អ្នករាល់គ្នាបានភ្លឺ ជាគំរូមួយនៅមុខអ្នក
ដទៃ ។

ម៉ាថាយ ២២:៣៦–៣៩ ។ ចូរស្រឡាញ់ព្រះអម្ចាស់ ចូរស្រឡាញ់អ្នកជិតខាង
ខ្លួន ។

យ៉ូហាន ១៤:១៥ ។ បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់តាមបញ្ញត្តិរបស់ខ្ញុំចុះ ។

នីហ្វៃទី ១ ៣:៧ ។ ព្រះអម្ចាស់រៀបចំផ្លូវមួយឲ្យរក្សាព្រះបញ្ញត្តិទាំងឡាយរបស់
ទ្រង់ ។

ម៉ូសាយ ២:១៧ ។ តាមរយៈការបម្រើអ្នកដទៃ នោះយើងបម្រើដល់ព្រះ ។

ម៉ូសាយ ២:៤១ ។ ការគោរពប្រតិបត្តិនាំមកនូវពរជ័យ និង សុភមង្គល ។

អាលម៉ា ៤១:១០ ។ សេចក្ដីទុច្ចរិតពុំដែលជាសុភមង្គលឡើយ ។

មរ៉ូណៃ៧:៤៥, ៤៧–៤៨ ។ សេចក្ដីសប្បុរសគឺជាសេចក្ដីស្រឡាញ់ដ៏សុទ្ធសាធនៃ
ព្រះគ្រីស្ទ ។

គ. និង ស. ១៨:១៥–១៦ ។ អំណរក្នុងការនាំព្រលឹងជាច្រើនមកកាន់
ព្រះយេស៊ូវគ្រីស្ទ

គ. និង ស. ៦៤:៩–១១ ។ យើងត្រូវបានតម្រូវឲ្យអត់ទោសដល់មនុស្សទាំង
អស់ ។

គ. និង ស. ៨៩:១៨–២១ ។ ពរជ័យទាំងឡាយនៃពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ។

ថ្នាក់សិក្ខាសាលា និង
ថ្នាក់វិទ្យាស្ថានសាសនា

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

CAMBODIAN

4 02150 15258 3
15015 258